# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 18-Jan-2013, 15:19
CMS/CFO: Uch Arun

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

## សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលពាក់ព័ន្ធនឹងច្បាប់ជាធរមាន

---

**ដាក់ដោយ៖**

**មេធាវីការពារក្តីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

មេធាវី Arthur VERCKEN

មេធាវី Jacques VERGÈS

**ដាក់ជូន៖**

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យូរ ឧត្តរា

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

**ជំនួយការ៖**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Shéhérazade BOUARFA

កញ្ញា Mathilde CHIFFERT

កញ្ញា អ៊ុច ស្រីផាត់

កញ្ញា ជុន សុធារី

លោក Pierre TOUCHE

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew CAYLEY

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

**ក្រុមមេធាវីការពារក្តីទាំងអស់**

# គោរពជូនអង្គជំនុំជម្រះសាលាដំបូង

## I- <u>ច្បាប់ជាធរមានចំពោះឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០១ ÷ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ</u>

១. យោងតាមគោលការណ៍នីត្យានុកូលភាព ច្បាប់ដែលត្រូវយកមកអនុវត្ត នៅក្នុងក្របខ័ណ្ឌនៃសំណុំរឿង ០០២/០១ ជាច្បាប់ដែលនៅជាធរមាន ចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៧ ខែ មករា ឆ្នាំ ១៩៧៩[1]។ តាមរយៈសារណានេះ យើងត្រូវកំណត់និយមន័យនៃឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងទម្រង់នៃការទទួលខុសត្រូវ ដែលបានចោទប្រកាន់ ដែលនឹងត្រូវយកមកអនុវត្តចំពោះមុខយុត្តាធិការពេលវេលារបស់ អ.វ.ត.ក។

២. នៅក្នុងសាលដីកា **ឌុច** អង្គជំនុំជម្រះតុលាការកំពូលបានរំឭកថា អង្គជំនុំជម្រះសាលាដំបូងមានកាតព្វកិច្ចក្នុងការធានាថា ការបកស្រាយនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការអនុវត្តនិយមន័យនោះ មិនមែនជាការធ្វើវិសោធនកម្មច្បាប់ដែលមានអានុភាពប្រតិសកម្មចំពោះនិយមន័យដែលមានសុពលភាព នៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ១ ៩៧៩ នោះឡើយ[2]។

---

[1] សាលដីកាលើរឿងក្តី កាំង ហ្គេកអ៊ាវ ហៅ ឌុច ("សាលដីកាឌុច") ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ F28 កថាខណ្ឌ ៩៧៖ *"អង្គជំនុំជម្រះនៃ អ.វ.ត.ក ត្រូវមានកាតព្វកិច្ចក្នុងការសម្រេចថា ការកំណត់អំពីធាតុផ្សំនៃឧក្រិដ្ឋកម្ម ឬទម្រង់នៃការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនេះ អាចយកមកអនុវត្តបាននៅក្នុងដែនកំណត់យុត្តាធិការពេលវេលារបស់ខ្លួន ហើយជនជាប់ចោទត្រូវតែអាចយល់ដឹងជាមុនថាជាបទល្មើស និងដឹងជាមុនថាមានច្បាប់ចែង។ បន្ថែមពីលើនេះទៀត អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ថាការពិនិត្យឡើងវិញដោយប្រុងប្រយ័ត្ន និងដោយមានសំអាងហេតុអំពីការកំណត់ទាំងនេះ មានសារៈសំខាន់ចាំបាច់ណាស់ក្នុងការធានាអំពីធម្មានុរូបរបស់ស្ថាប័ន និងសេចក្តីសម្រេចរបស់ អ.វ.ត.ក"*។

[2] ដូចយោងខាងលើ កថាខណ្ឌ ១០០។ ៖ *"ការអនុវត្តយុត្តាធិការរបស់អង្គជំនុំជម្រះត្រូវបានកម្រិតដោយនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចដែលមានកំណត់តាមច្បាប់អន្តរជាតិ នៅពេលដែលអំពើល្មើសត្រូវបានចោទប្រកាន់បានប្រព្រឹត្តឡើង។ ម្យ៉ាងវិញទៀត មាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រួមជាមួយនឹងបញ្ជីរាយឈ្មោះនៃបទល្មើសនានាក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែល អ.វ.ត.ក មានយុត្តាធិការដែលសន្មតទុកជាមុនទៅលើឧក្រិដ្ឋកម្មទាំងនោះ មិនអាចត្រូវបានបកស្រាយថា ជាវិសោធនកម្មច្បាប់ដែលមានអានុភាពប្រតិសកម្មចំពោះនិយមន័យនេះ នោះឡើយ។"*

៣. ក្នុងករណីគ្មានអត្ថបទច្បាប់ចែង ច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រូវយកមកអនុវត្ត។ ក៏ប៉ុន្តែ បន្ទាប់ពីតុលាការ Nuremberg មក គេត្រូវរង់ចាំរហូតដល់ឆ្នាំ១៩៩៦ ទើបគណៈកម្មាធិការសិទ្ធិមនុស្សអន្តរជាតិ ដែលត្រូវបានបង្កើតឡើងដោយមហាសន្និបាតអង្គការសហប្រជាជាតិ(“មហាសន្និបាត”) ធ្វើការតាក់តែងសេចក្តីព្រាងក្រមស្តីពីឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិ ដោយកំណត់និយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ និយមន័យនេះត្រូវបាន *“ដកស្រង់ចេញពីលក្ខន្តិកៈតុលាការ Nuremberg ទៅតាមការបកស្រាយ និងអនុវត្តរបស់តុលាការនេះ។ គណៈកម្មាធិការនេះក៏គិតគូរផងដែរទៅលើការវិវត្តនៃនីតិអន្តរជាតិ ដែលកើតមានចាប់តាំងពីតុលាការនេះចេញសាលក្រមមក”* [3]។ ទោះបីយុត្តិសាស្ត្រក្រោយៗមកទៀតរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិនានា អាចមានសារៈប្រយោជន៍ដល់ការបកស្រាយនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងលក្ខខណ្ឌណាមួយក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលបានគូសបញ្ជាក់ថា យុត្តិសាស្ត្រនេះមិនមានអនុភាពចងកាតព្វកិច្ច អ.វ.ត.ក នោះទេ ហើយត្រូវប្រើប្រាស់ដោយប្រុងប្រយ័ត្ន[4]។

៤. លោក ខៀវ សំផន ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាអំពើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស ការជម្លៀសដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ)។ មាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងថា បទល្មើសដាក់លាក់ទាំងនេះ គឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប្រសិនបើត្រូវបានប្រព្រឹត្ត ***“ក្នុងក្របខ័ណ្ឌនៃការវាយប្រហារជាទូទៅ ឬដោយមានការរៀបចំប្រឆាំងទៅលើប្រជាជនស៊ីវិល ដោយមូលហេតុជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា ណាមួយ”*** [5]។ នេះជាធាតុផ្សំដែលសហព្រះរាជអាជ្ញាមានកាតព្វកិច្ចត្រូវបង្ហាញ។

---

[3] របាយការណ៍របស់គណៈកម្មាធិការសិទ្ធិមនុស្សអន្តរជាតិ ស្តីពីការងារនៃកិច្ចប្រជុំលើកទី ៤៨ សេចក្តីព្រាងក្រមស្តីពីឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិ (“សេចក្តីព្រាងក្រមរបស់គណៈកម្មាធិការសិទ្ធិមនុស្សអន្តរជាតិ”) ថ្ងៃទី ០៦ ខែ ឧសភា ដល់ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ មហាសន្និបាត ឯកសារផ្លូវការ កិច្ចប្រជុំលើកទី៥១ ឯកសារបន្ថែមលេខ 10, A/51/10 ទំព័រ ១១៥។

[4] ដូចយោងខាងលើ កថាខណ្ឌ ៩៧។

[5] មាត្រា ៥ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក”)។

### ១. <u>ធាតុផ្សំសត្យានុម័តិៈ ចរិតលក្ខណៈនៃការវាយប្រហារ</u>

៥. រាល់និយមន័យទាំងអស់ ទោះជាក្នុងសម័យកាលណាក៏ដោយ កំណត់ថា ការវាយប្រហារត្រូវ៖ ក) មានលក្ខណៈទូទៅ ឬដោយមានការរៀបចំ និង ខ) ប្រឆាំងទៅលើប្រជាជនស៊ីវិល។ ផ្ទុយទៅវិញ មិនមានការឯកភាពជាឯកច្ឆន្ទចំពោះបរិបទនៃការវាយប្រហារនោះទេ។

៦. ចំពោះតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ការវាយប្រហារត្រូវប្រព្រឹត្ត ក្នុងក្របខ័ណ្ឌនៃជម្លោះប្រដាប់អាវុធ[6]។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា តម្រូវឱ្យការវាយប្រហារត្រូវធ្វើឡើង ក្នុងលក្ខណៈរើសអើង ដោយមូលហេតុជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា។

៧. មាត្រា៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ឯកភាពតាមនិយមន័យនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់ប្រទេសរ្វ៉ាន់ដា ដោយកំណត់ថាការវាយប្រហារត្រូវធ្វើឡើង ក្នុងលក្ខណៈរើសអើង។

៨. ក៏ប៉ុន្តែ នៅក្នុងដីកាសន្និដ្ឋានស្ថាពរ សហព្រះរាជអាជ្ញាផ្អែកលើយុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្ម អន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ជាពិសេស សាលដីកាលើបណ្តឹងឧទ្ធរណ៍ ក្នុងរឿងក្តី *Kunarac* ដើម្បីអះអាងថា *"សម្រាប់គោលបំណងបង្កើតឱ្យមានឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការវាយប្រហារពុំកំណត់ត្រឹមតែការប្រើប្រាស់កងកម្លាំងប្រដាប់អាវុធឡើយ ពោលគឺរាប់បញ្ចូល ទាំងការធ្វើបាបប្រជាជនស៊ីវិលផង។ ការវាយប្រហារពុំចាំបាច់ជាការវាយប្រហារខាងយោធា ឬ*

---

[6] មាត្រា ៥ នៃលក្ខន្តិកៈតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ចែងថា *"តុលាការអន្តរជាតិមានយុត្តាធិការ ក្នុងការវិនិច្ឆ័យទោសជនដែលត្រូវបានសន្មតថាជាអ្នកទទួលខុសត្រូវលើឧក្រិដ្ឋកម្មនានាដូចខាងក្រោម ប្រសិនបើឧក្រិដ្ឋកម្មទាំងនោះត្រូវបានប្រព្រឹត្ត* ***ក្នុងពេលជម្លោះប្រដាប់អាវុធ*** *ជាលក្ខណៈអន្តរជាតិ ឬជាតិ និងប្រឆាំងនឹងប្រជាជនស៊ីវិលណាមួយ"*។ ឧទាហរណ៍ សូមមើល៖ *រដ្ឋអាជ្ញា ទល់នឹង Dragoljub Kunarac, Radomir Kovac និង Zoran Vukovic*, IT-96-23 & IT-96-23/1-A, សាលដីកា ("សាលដីកា *Kunarac*") ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០២ កំណត់សម្គាល់ចុងទំព័រ ៩៩។ *រដ្ឋអាជ្ញា ទល់នឹង Momcilo Perisić*, IT-04-81-T, សាលក្រម ("សាលក្រម *Perisić*") ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១១ កថាខណ្ឌ ៧៩ *"ដើម្បីឱ្យមាត្រា ៥ នៃលក្ខន្តិកៈ ដែលចោទលទោសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អាចអនុវត្តបាន ចាំបាច់ត្រូវបង្ហាញថា៖ ១) មានជម្លោះប្រដាប់អាវុធ និង ២) អំពើចោទប្រកាន់មានទំនាក់ទំនងភូមិសាស្ត្រ និងពេលវេលា ជាមួយជម្លោះប្រដាប់អាវុធ"*។

*ការវាយប្រហារជាផ្នែកមួយនៃជម្លោះប្រដាប់អាវុធឡើយ”*[7]។ ក៏ប៉ុន្តែ សាលក្រម *Kunarac* ដែលតម្កល់ដោយសាលដីកា សម្រេចថា៖ *“ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការវាយប្រហារពុំកម្រិតត្រឹមការដឹកនាំអរិភាពនោះទេ គឺអាចរាប់បញ្ចូលទាំងស្ថានភាពនៃការធ្វើបាបបុគ្គលដែលមិនចូលរួមដោយផ្ទាល់ក្នុងអរិភាពនោះ ដូចជា ជនជាប់ឃុំ ជាដើម។ ការទទួលយកទាំងពីរនៃពាក្យនេះចេញមកពីគំនិតតែមួយ គឺថាសង្គ្រាមជាការប្រឈមមុខដាក់គ្នារវាងកម្លាំងប្រដាប់អាវុធ ឬក្រុមប្រដាប់អាវុធ ហើយតាមផ្លូវច្បាប់ មិនត្រូវប៉ះពាល់ដល់ប្រជាជនស៊ីវិលនោះឡើយ”*[8]។ ដូច្នេះ ការតម្រូវឲ្យមានជម្លោះប្រដាប់អាវុធ នៅតែមានសុពលភាព ក្នុងគ្រប់ករណីទាំងអស់ ហើយវាមិនត្រឹមត្រូវនោះទេ ដែលសហព្រះរាជអាជ្ញាអះអាងថា ត្រឹមតែការធ្វើបាបប្រជាជនស៊ីវិលបង្កើតឲ្យមានជាការវាយប្រហារនោះ។

៩. ដូច្នេះ ប្រសិនបើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិអាចត្រូវបានប្រព្រឹត្ត ក្នុងពេលមានសន្តិភាព ចាំបាច់ត្រូវបញ្ចូលលក្ខណៈវិនិច្ឆ័យបន្ថែម ដើម្បីបែងចែកឲ្យបានច្បាស់រវាងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មនៃនីតិរួម[9]។ អាស្រ័យហេតុនេះ ប្រសិនបើគ្មានជម្លោះប្រដាប់អាវុធ បញ្ហានៃការចង់ដឹងថាតើពាក្យវាយប្រហារប្រឆាំងនឹង “ប្រជាជនស៊ីវិល” មាននិយមន័យដូចម្តេច បានចោទឡើង។

១០. គណៈកម្មាធិការសិទ្ធិមនុស្សអន្តរជាតិ បានយល់ឃើញថា ច្បាប់ទំនៀមទម្លាប់អន្តរជាតិមិនតម្រូវឲ្យមានទំនាក់ទំនងរវាងជម្លោះប្រដាប់អាវុធ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះទេ។ ក៏ប៉ុន្តែ គណៈកម្មាធិការបានកំណត់ថា ដើម្បីអាចចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បទល្មើស

---

[7] ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា (វិធាន ៦៦) ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១០ ឯកសារ D390 កថាខណ្ឌ ១២៤៤។

[8] *រដ្ឋអាជ្ញា ទល់នឹង Dragoljub Kunarac, Radomir Kovac និង Zoran Vukovic*, IT-96-23-T & IT-96-23/1-T, សាលក្រម (“សាលក្រម *Kunarac*”) ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០១ កថាខណ្ឌ ៤១៦។ និយមន័យនេះត្រូវបានបញ្ជាក់ដោយអង្គជំនុំជម្រះតុលាការកំពូល កំណត់សម្គាល់ចុងទំព័រ ១៥៧។

[9] គណៈកម្មការត្រៀមសម្រាប់បង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ A/AC.249/CRP.2/add.3/Rev.1 ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ១៩៩៦៖ *“គណៈប្រតិភូជាច្រើនបានផ្តល់សារៈសំខាន់ជាពិសេសទៅលើលក្ខណៈវិនិច្ឆ័យទូទៅ សម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដើម្បីញែកឧក្រិដ្ឋកម្មនេះចេញពីឧក្រិដ្ឋកម្មធម្មតា នៅក្រោមច្បាប់ជាតិ និងដើម្បីជៀសវាងការជ្រៀតជ្រែកចូលយុត្តាធិការតុលាការជាតិទៅលើឧក្រិដ្ឋកម្មធម្មតា ហើយបានពិភាក្សាជាចម្បងអំពីលក្ខណៈវិនិច្ឆ័យដែលមានចែងនៅក្នុងមាត្រា ៣ នៃលក្ខន្តិកៈតុលាការរ៉ាន់ដា”* ទំព័រ ១។

ត្រូវបានប្រព្រឹត្ត *"តាមការញុះញង់ ឬក្រោមការដឹកនាំរបស់រដ្ឋាភិបាល អង្គការចាត់តាំង ឬក្រុមណាមួយ"*[10]។ នៅក្នុងរឿងក្តី *Bagilishema* តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានផ្អែកលើនិយមន័យរបស់គណៈកម្មាធិការសិទ្ធិមនុស្សអន្តរជាតិ ដើម្បីទាញសន្និដ្ឋានថាជាធម្មតាការវាយប្រហារជាទូទៅ ឬជាប្រព័ន្ធ ទាមទារឲ្យមានការរៀបចំផែនការជាចាំបាច់[11]។ តុលាការបានបន្ថែមទៀតថា លក្ខណៈវិនិច្ឆ័យដែលថា ការវាយប្រហារត្រូវធ្វើឡើងប្រឆាំងទៅលើប្រជាជនស៊ីវិល សន្មតជាមុននូវអត្ថិភាពនៃផែនការណាមួយ ហើយតាមធម្មជាតិរបស់វា ធាតុផ្សំរើសអើងនៃការវាយប្រហារអាចមានទៅបាន ក្នុងទម្រង់ជាផលវិបាកនៃនយោបាយណាមួយ[12]។

១១. ចរិតលក្ខណៈទាំងបីនៃការវាយប្រហារ ដែលជាមូលដ្ឋានឲ្យតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា ទាញជាសេចក្តីសន្និដ្ឋាន ពោលគឺការវាយប្រហារ "ជាទូទៅ ឬជាប្រព័ន្ធ" "ធ្វើឡើងប្រឆាំងនឹងប្រជាជនស៊ីវិល" និង "ធាតុផ្សំរើសអើង" មានចែងនៅក្នុងមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

១២. ដូច្នេះ ដើម្បីបង្កើតបានជាធាតុផ្សំសត្យានុម័តិនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ សហព្រះរាជអាជ្ញាត្រូវបង្ហាញថា៖ ក) ឧក្រិដ្ឋកម្មចោទប្រកាន់ត្រូវបានប្រព្រឹត្ត[13] ខ) ឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្ត នៅក្នុងក្របខ័ណ្ឌនៃការវាយប្រហារ គ) ការវាយប្រហារមានលក្ខណៈជាទូទៅ ឬជាប្រព័ន្ធ ឃ) ធ្វើឡើងប្រឆាំងនឹងប្រជាជនស៊ីវិល ង) ដោយមូលហេតុជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា ច) ជាការអនុវត្ត ឬបន្តនយោបាយរបស់រដ្ឋ ឬអង្គការចាត់តាំងណាមួយ ដែលមានគោលដៅវាយប្រហារបែបនេះ។

---

[10] សេចក្តីព្រាងក្រមរបស់គណៈកម្មាធិការសិទ្ធិមនុស្សអន្តរជាតិ ទំព័រ ១១៥។

[11] *រដ្ឋអាជ្ញា ទល់នឹង* Ignace Baglishemana, ICTR-95-1A-T, ចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០១ សាលក្រម កំណត់សម្គាល់ចុងទំព័រ ៧១។

[12] ដូចយោងខាងលើ កថាខណ្ឌ ៧៨។

[13] ឧទាហរណ៍ អំពីមនុស្សឃាត សូមមើល៖ សាលក្រម *Milutinović*៖ *"ដើម្បីបង្ហាញថាអំពើមនុស្សឃាតជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានប្រព្រឹត្ត រដ្ឋអាជ្ញាត្រូវបង្ហាញអំពី (ក) ធាតុផ្សំសត្យានុម័តិ និងធាតុផ្សំអត្តនោម័តិ នៃអំពើមនុស្សឃាត និង (ខ) ល័ក្ខខ័ណ្ឌតម្រូវទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"* កថាខណ្ឌ ១៧៣។

## ២. <u>ធាតុផ្សំអត្តនោម័តិ ៖ ទំនាក់ទំនងរវាងការដឹងឮរបស់ជនជាប់ចោទអំពីការវាយប្រហារ និងអំពើដែលបានប្រព្រឹត្ត ក្នុងក្របខ័ណ្ឌនៃការវាយប្រហារនេះ</u>

១៣. ដោយឡែក យើងត្រូវវិភាគអំពីស្ថានភាព ដែលថាជនជាប់ចោទទំនងមិនមែនជាចារីពិតប្រាកដនៃឧក្រិដ្ឋកម្មនោះទេ។ ជាក់ស្តែង ស្ថានភាពនេះត្រូវគ្នានឹងការជំនុំជម្រះក្តីយើងនេះ។

១៤. នៅក្នុងសាលក្រម **ឌុច** អង្គជំនុំជម្រះសាលាដំបូងបានផ្អែកលើយុត្តិសាស្ត្រ *Kunarac* ដើម្បីកំណត់ធាតុផ្សំអត្តនោម័តិនៃការវាយប្រហារ[14]។ អង្គជំនុំជម្រះបានបញ្ជាក់យ៉ាងដូច្នេះថា៖ *"អំពើរបស់ជនជាប់ចោទត្រូវតែជា**ផ្នែកមួយនៃការវាយប្រហារជាសព្វានុម័ត** ទោះជាអំពើនោះជាអំពើប្រភេទណា ឬមានផលវិបាកយ៉ាងណាក៏ដោយ ដរាបណាអំពើទាំងនោះមិនត្រូវបានកាត់ផ្តាច់ទាំងស្រុងចេញពីបរិបទនៃការវាយប្រហារ"*[15]។ ប៉ុន្តែ នៅក្នុងរឿងក្តីទាំងពីរ *Kunarac* និង **ឌុច** ជនជាប់ចោទជាចារីផ្ទាល់នៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់។

១៥. ដូច្នេះ ក្នុងសាលក្រមនៃសំណុំរឿងយើងនេះ អង្គជំនុំជម្រះនឹងជួបបញ្ហាក្នុងការកំណត់អំពីលក្ខណៈវិនិច្ឆ័យដែលអាចឱ្យភ្ជាប់ទំនាក់ទំនងជាយថាហេតុ រវាងជនជាប់ចោទ និងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់។

១៦. យុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិនានា បានខកខានតាំងពីយូរយារណាស់មកហើយក្នុងការបែងចែកឱ្យច្បាស់រវាងធាតុផ្សំអត្តនោម័តិចំពោះជនជាប់ចោទ និងធាតុផ្សំអត្តនោម័តិចំពោះចារីពិតប្រាកដនៃឧក្រិដ្ឋកម្ម។ កង្វះខាតនេះត្រូវបានរិះគន់ដោយឯកសារវិភាគច្បាប់នានា[16] ហើយត្រូវបានកែតម្រូវដោយយុត្តិសាស្ត្រនៅក្នុងសាលក្រម *Milutinović*[17]។

---

[14] សាលក្រមលើរឿងក្តី កាំង ហ្កេកអ៊ាវ ហៅ ឌុច ("សាលក្រម ឌុច") ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ ឯកសារ E188 កថាខណ្ឌ ៣១៨-៣១៩។

[15] សាលក្រម ឌុច កថាខណ្ឌ ៣១៨។

[16] ឧទាហរណ៍ សូមមើល Gideon Boas, James L. Bischoff និង Natalie L. Reid *បណ្ណាល័យច្បាប់ព្រហ្មទណ្ឌ ភាគ ២ - ធាតុផ្សំនៃឧក្រិដ្ឋកម្ម យោងតាមច្បាប់អន្តរជាតិ* Cambridge University Press (ឆ្នាំ ២០១១) ទំព័រ ៣៥-៤១។

[17] *រដ្ឋអាជ្ញា ទល់នឹង Milan Milutinović*, IT-05-87-T, សាលក្រម ("សាលក្រម *Milutinović*") ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៩ កថាខណ្ឌ ១៥៣ ដល់ ១៦២។

១៧. នៅក្នុងរឿងក្តី *Milutinović* តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានបញ្ជាក់ថា ដើម្បីបង្កើតឲ្យមានឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវមានធាតុផ្សំដូចតទៅ៖ ១) អំពើរបស់ចារីពិតប្រាកដនៃឧក្រិដ្ឋកម្មស្ថិតនៅក្នុងបរិបទនៃការវាយប្រហារ[18] និង ២) ជនជាប់ចោទដឹងឮអំពីការវាយប្រហារ ទោះជាខ្លួនជាចារីពិតប្រាកដ ឬមិនមែនក៏ដោយ[19]។

១៨. ម្យ៉ាងវិញទៀត នៅក្នុងរឿងក្តី *Milutinović* ដដែល តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានសម្រេចថាក្នុងករណីជនជាប់ចោទមិនមែនជាចារីពិតប្រាកដនៃឧក្រិដ្ឋកម្ម រដ្ឋអាជ្ញាត្រូវបង្ហាញអំពីអត្ថិភាពនៃទំនាក់ទំនងផ្ទាល់ ឬជិតស្និទ្ធគ្រប់គ្រាន់ រវាងជនជាប់ចោទ និងការប្រព្រឹត្តអំពើដែលបានចោទប្រកាន់។ នៅពេលទំនាក់ទំនងនេះមានភាពទន់ខ្សោយពេក តុលាការបានវិនិច្ឆ័យថា មិនមានឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះទេ គឺដូចករណីក្នុងស្ថានភាពជួយ និងជំរុញដែរ[20]។ តុលាការយល់ឃើញថា ទំនាក់ទំនងនេះស្តែងឡើងច្បាស់លាស់បំផុត នៅពេលជននោះមានចេតនាឲ្យកើតមានឧក្រិដ្ឋកម្ម មានន័យថាជននោះបានប្រព្រឹត្ត រៀបចំផែនការ បញ្ជា ឬញុះញង់[21]។

១៩. ដូច្នេះ នៅក្នុងការជំនុំជម្រះក្តីយើងនេះ បទល្មើសជាក់លាក់អាចត្រូវបានចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយទោះបីជាចារីពិតប្រាកដនៃឧក្រិដ្ឋកម្មមិនដឹងអំពីបរិបទដែលខ្លួនប្រព្រឹត្ត ដោយសារតែជនជាប់ចោទ ដែលបានរៀបចំផែនការ បញ្ជា ឬញុះញង់ឲ្យមានការប្រព្រឹត្តពីចារី (ឬសមាជិកនៃសហឧក្រិដ្ឋកម្មរួម) ដឹងថាអង្គហេតុដែលបង្កើតបានជាឧក្រិដ្ឋកម្មចោទប្រកាន់ ស្ថិត

---

[18] សាលក្រម *Milutinović* កថាខណ្ឌ ១៥២។

[19] ដូចយោងខាងលើ កថាខណ្ឌ ១៥៣ ដល់ ១៥៦។

[20] ដូចយោងខាងលើ កថាខណ្ឌ ១៥៧។

[21] ដូចយោងខាងលើ កថាខណ្ឌ ១៥៨៖ *"ចំពោះបទល្មើសជាក់លាក់ ដែលត្រូវកំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ផ្អែកលើការដឹងឮរបស់ជនណាម្នាក់ អំពីបរិបទនៃការប្រព្រឹត្តបទល្មើសនោះ ទំនាក់ទំនងរវាងជននោះ និងការប្រព្រឹត្តបទល្មើស ត្រូវមានទំនាក់ទំនងផ្ទាល់ និងជិតស្និទ្ធគ្រប់គ្រាន់។ តាមទស្សនៈរបស់អង្គជំនុំជម្រះសាលាដំបូង ភាពផ្ទាល់ និងជិតស្និទ្ធិគ្រប់គ្រាន់នៃទំនាក់ទំនងនោះ ត្រូវបានកំណត់ដោយលក្ខខណ្ឌតម្រូវថា ជននោះមានចេតនាឲ្យបទល្មើសកើតឡើង ក្នុងទម្រង់បួននៃការទទួលខុសត្រូវដូចមានចែងនៅក្នុងលក្ខន្តិកៈ៖ ប្រព្រឹត្ត រៀបចំផែនការ បញ្ជា និងញុះញង់។ ក្រោមទម្រង់នៃការទទួលខុសត្រូវទាំងនេះ ការដឹងឮអំពីបរិបទនៃបទល្មើសគឺជាផ្នែកមួយនៃដំណើរការផ្លូវចិត្ត ជាលទ្ធផលនៃការប្រព្រឹត្តបទល្មើសនោះ"*។

នៅក្នុងបរិបទនៃការវាយប្រហារនោះ[22]។

២០. នៅពេលនេះ យើងនឹងកត់សម្គាល់ឃើញថា តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានសង្កត់ធ្ងន់ជាពិសេសទៅលើលក្ខខណ្ឌតម្រូវឱ្យបង្ហាញភស្តុតាងថាមានទំនាក់ទំនងផ្ទាល់ រវាងឧក្រិដ្ឋកម្ម និងជនជាប់ចោទ[23]។ ជាក់ស្តែង តុលាការ បានបែងចែកយ៉ាងច្បាស់រវាងការវិភាគនេះ និងបញ្ហាទម្រង់នៃការទទួលខុសត្រូវ។

២១. ដូច្នេះ ចៅក្រមត្រូវវិភាគជាពីរដំណាក់កាល ទីមួយ ត្រូវកំណត់ថាតើលក្ខខណ្ឌធាតុផ្សំអត្ថនោម័តិនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានបំពេញដែរឬទេ ទីពីរ ត្រូវកំណត់ថាតើទម្រង់នៃការទទួលខុសត្រូវអាចត្រូវបានទទួលយកដែរឬទេ។ ការវិភាគអំពីធាតុផ្សំអត្ថនោម័តិនឹងមិនអាចលាយឡំជាមួយការវិភាគទម្រង់នៃការទទួលខុសត្រូវនោះទេ។

## ៣. ច្បាប់ជាធរមានចំពោះបទល្មើសជាក់លាក់ ÷ ករណីធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងករណីអំពើអមនុស្សធម៌ផ្សេងទៀត

២២. យោងតាមគោលការណ៍អប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ លោក ខៀវ សំផន អាចត្រូវបានកាត់ទោស តែចំពោះអំពើជាបទឧក្រិដ្ឋ ក្នុងអំឡុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ប៉ុណ្ណោះ និងអនុលោមតាមនិយមន័យដែលអនុវត្ត នៅសម័យនោះ។

២៣. បទល្មើសជាក់លាក់ជា "ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ" និង "អំពើអមនុស្សធម៌

[22] ដូចយោងខាងលើ កថាខណ្ឌ ១៥៨៖ *"ទីមួយ នៅពេលល័ក្ខខ័ណ្ឌអំពីទំនាក់ទំនងទាំងពីរត្រូវបានបំពេញដោយចារីពិតប្រាកដ ដោយសារជននោះប្រព្រឹត្តអំពីសកម្ម ឬអកម្ម ជាផ្នែកមួយនៃការវាយប្រហារ ហើយដឹងថាទង្វើរបស់ខ្លួនជាផ្នែកមួយនៃការវាយប្រហារ។ ទីពីរ ទោះបីជាចារីពិតប្រាកដមិនដឹងអំពីបរិបទនៃទង្វើប្រព្រឹត្តបទល្មើស នៅពេលអ្នករៀបចំផែនការ អ្នកបញ្ជា អ្នកញុះញង់ ឬសមាជិកនៃសហឧក្រិដ្ឋកម្មរួម ដឹងថានេះគឺវាផ្នែកមួយនៃការវាយប្រហារ"*។

[23] ដូចយោងខាងលើ កថាខណ្ឌ ១៥៩៖ *"អង្គជំនុំជម្រះសង្កត់ធ្ងន់នៅទីនេះថា ការវិភាគនេះមិនត្រូវច្រឡំគ្នាជាមួយបញ្ហាថាតើជនជាប់ចោទមានការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាក់លាក់ ដែរឬទេ នោះទេ។ ខាងលើនេះគ្រាន់តែការកំណត់ធម្មតាថាតើឧក្រិដ្ឋកម្មនោះត្រូវបានប្រព្រឹត្តដែរឬទេ តែប៉ុណ្ណោះ"*។

ផ្សេងទៀត” ជាប្រភេទមិនកំណត់[24]។ ក៏ប៉ុន្តែ ដើម្បីបង្កើតឲ្យមានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បទល្មើសទាំងនេះត្រូវមានកម្រិតធ្ងន់ធ្ងរស្មើនឹងបទល្មើសជាក់លាក់ផ្សេងទៀត[25]។

## ក. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ

២៤. ពាក្យ “ធ្វើទុក្ខបុកម្នេញ” គ្របអំពើផ្សេងៗជាច្រើន។

២៥. យោងតាមមាត្រា ៦(គ) នៃលក្ខន្តិកៈតុលាការ Nuremberg ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិគឺជា *“(...) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា នៅពេលអំពើ ឬការធ្វើទុក្ខបុកម្នេញទាំងនេះត្រូវបានប្រព្រឹត្ត* ***ជាការអនុវត្តឬ ដោយមានទំនាក់ទំនងជាមួយឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការ*** *ទោះជាអំពើ ឬការធ្វើទុក្ខបុកម្នេញទាំងនោះ ជាការរំលោភបំពាន ឬមិនរំលោភបំពានច្បាប់ជាតិរបស់ប្រទេសកើតហេតុក៏ដោយ”*[26]។ម្យ៉ាងវិញទៀត ចៅក្រមនៅតុលាការ Nuremberg យល់ឃើញថា ដោយសារគ្មានទំនាក់ទំនងនេះ ការធ្វើទុក្ខបុកម្នេញ ដែលបានប្រព្រឹត្តឡើងចំពោះជនជាតិជ្វីប មុនឆ្នាំ១៩៣៩ (កាលបរិច្ឆេទកំណត់យកសម្រាប់ការចាប់ផ្តើមសង្គ្រាម) ទោះជាគួរឲ្យរន្ធត់យ៉ាងណាក៏ដោយ មិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះទេ[27]។ លក្ខន្តិកៈទីក្រុងរ៉ូមក៏កំណត់និយមន័យនៃការធ្វើទុក្ខបុកម្នេញ *“នៅក្នុងទំនាក់ទំនង*

---

[24] *រដ្ឋអាជ្ញា ទល់នឹង Blagojević et Jokić*, IT-02-60-T, សាលក្រម (“សាលក្រម *Blagojević*”) ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ កថាខណ្ឌ ៦២៤។

[25] សាលក្រម *Milutinović* កថាខណ្ឌ ១៧៨-១៧៩។ *រដ្ឋអាជ្ញា ទល់នឹង Tihomir Blaskić*, IT-95-14-A, សាលដីកា (“សាលដីកា *Blaskić*”) ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៤ កថាខណ្ឌ ១៣១។

[26] លក្ខន្តិកៈតុលាការយោធាអន្តរជាតិ ទីក្រុងឡុងដ៍ ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ១៩៤៥។ លក្ខន្តិកៈនេះមាននៅវែបសាយត៍៖ « http://www.icrc.org/dih.nsf/FULL/350 »។

[27] តុលាការយោធាអន្តរជាតិ (Nuremberg) ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ១៩៤៦ សាលក្រមមាននៅវែបសាយត៍៖ http://werle.rewi.hu-berlin.de/IMTJudgment.pdf។ *“ទស្សនៈនយោបាយធ្វើទុក្ខបុកម្នេញ បង្ក្រាប និងសម្លាប់ជនស៊ីវិល ដែលទំនងជាប្រឆាំងនឹងរដ្ឋាភិបាល ត្រូវបានអនុវត្តយ៉ាងសាហាវឃោរឃៅបំផុត នៅប្រទេសអាល្លឺម៉ង់ មុនសង្គ្រាមឆ្នាំ១៩៣៩ (...)។ ដើម្បីកំណត់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើមុនពេលផ្ទុះសង្គ្រាម ត្រូវបានប្រព្រឹត្ត ជាការអនុវត្ត ឬដោយមានទំនាក់ទំនងជាមួយឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការតុលាការ។ តុលាការយល់ឃើញថា ទោះបីជាឧក្រិដ្ឋកម្មជាច្រើនមានលក្ខណៈគួរឲ្យភ័យខ្លាច និងរន្ធត់យ៉ាងណាក៏ដោយ ក៏មិនមានភស្តុតាងគ្រប់គ្រាន់បង្ហាញថា អំពើទាំងនោះត្រូវបានប្រព្រឹត្ត ជាការអនុវត្ត ឬដោយមានទំនាក់ទំនងជាមួយឧក្រិដ្ឋកម្មនោះទេ”*។

*ជាមួយអំពើណាមួយ ដែលបានចែងនៅក្នុងកថាខណ្ឌនេះ ឬបទល្មើសព្រហ្មទណ្ឌណាមួយ ដែលស្ថិតក្នុងយុត្តាធិការតុលាការ"*[28]។

២៦. ខុសពីតុលាការពីរខាងលើ ចៅក្រមតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី មិនតម្រូវឲ្យមានទំនាក់ទំនងរវាងអំពើធ្វើទុក្ខបុកម្នេញ និងឧក្រិដ្ឋកម្មអន្តរជាតិផ្សេងទៀតឡើយ។ សេចក្តីព្រាងក្រមរបស់គណៈកម្មាធិការសិទ្ធិមនុស្សអន្តរជាតិមិនមានចែងអំពីបញ្ហានេះទេ។ គ្មានប្រយោជន៍អ្វីក្នុងការពិភាក្សាដេញដោលចង់ដឹងថា តើច្បាប់ទំនៀមទម្លាប់អន្តរជាតិតម្រូវជានិច្ចឲ្យមានទំនាក់ទំនងនេះ នៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ឬក៏អត់នោះទេ។ ជាការពិត កម្ពុជាជារដ្ឋភាគីនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ហើយច្បាប់អនុវត្តនៅកម្ពុជាសព្វថ្ងៃ ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺលក្ខន្តិកៈទីក្រុងរ៉ូម។ គោលការណ៍នីត្យានុកូលភាពកំណត់អំពីការអនុវត្តជាប្រតិសកម្មនូវច្បាប់ព្រហ្មទណ្ឌដែលផ្តន្ទាទោសស្រាលជាង។ ម្យ៉ាងវិញទៀត មាត្រា ៩ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើត អ.វ.ត.ក ចែងថា និយមន័យអនុវត្តចំពោះបទល្មើសជាក់លាក់ គឺនិយមន័យដូចបានកំណត់ក្នុងលក្ខន្តិកៈទីក្រុងរ៉ូម[29]។

២៧. ក្នុងលក្ខខណ្ឌទាំងនេះ សហព្រះរាជអាជ្ញាត្រូវបង្ហាញថា៖ ក) អំពើធ្វើទុក្ខបុកម្នេញមានកម្រិតធ្ងន់ធ្ងរស្មើនឹងបទល្មើសជាក់លាក់ផ្សេងទៀត ខ) មានទំនាក់ទំនងរវាងអំពើធ្វើទុក្ខបុកម្នេញទាំងនេះ និងបទល្មើសជាក់លាក់ផ្សេងទៀត ដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក។

## ខ. អំពើអមនុស្សធម៌ផ្សេងទៀត (ការជម្លៀស និងឃាត់ខ្លួនដោយបង្ខំ ការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស)

២៨. គណៈកម្មាធិការសិទ្ធិមនុស្សអន្តរជាតិកំណត់ថាអំពើសកម្ម ឬអកម្មណាមួយ ស្ថិតនៅក្នុងប្រភេទនៃអំពើអមនុស្សធម៌ផ្សេងទៀត ប្រសិនបើធាតុផ្សំទាំងនេះត្រូវបានបំពេញ៖ ក) មានភាពធ្ងន់ធ្ងរដូចគ្នានឹងបទល្មើសជាក់លាក់ផ្សេងទៀត *"ខ) អំពើនោះបង្កព្យសនកម្មដល់ជនណាម្នាក់ ដោយធ្វើឲ្យប៉ះ*

---

[28] មាត្រា ៧(១) នៃលក្ខន្តិកៈទីក្រុងរ៉ូម។

[29] មាត្រា ៩ នៃកិច្ចព្រមព្រៀង ចែងថា *"យុត្តាធិការលើរឿងក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញរួមមាន (...) ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចបានកំណត់ក្នុងលក្ខន្តិកៈទីក្រុងរ៉ូម នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ឆ្នាំ១៩៩៨"*។

*ពាល់ដល់បូរណភាពផ្លូវកាយ ឬផ្លូវចិត្ត សុខភាព ឬសេចក្តីថ្លៃថ្នូររបស់បុគ្គលនោះ"*[30]។

២៩. ក៏ប៉ុន្តែ ត្រឹមតែលក្ខណៈវិនិច្ឆ័យទាំងនេះត្រូវបានបំពេញ ដើម្បីប្រែក្លាយប្រភេទ "អំពើអមនុស្សធម៌ផ្សេងទៀត" ឲ្យទៅជាបទប្បញ្ញត្តិគ្មានដែនកំណត់ជាក់លាក់ ផ្ទុយនឹងគោលការណ៍នីត្យានុកូលភាព វាមិនគ្រប់គ្រាន់នោះ។

៣០. ពិសេសជាងនេះទៅទៀត ចំពោះការបាត់ខ្លួនដោយបង្ខំ យើងខ្ញុំសូមគូសបញ្ជាក់នៅពេលនេះថា ទោះបីជាសេចក្តីព្រាងក្រមរបស់គណៈកម្មាធិការសិទ្ធិមនុស្សអន្តរជាតិ កំណត់យកអត្ថិភាពនៃការបាត់ខ្លួនដោយបង្ខំ ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក៏ដោយ ក៏គណៈកម្មាធិការនេះខិតខំបញ្ជាក់ថា *"ការបាត់ខ្លួនដោយបង្ខំមិនមានចែងនៅក្នុងលិខិតុបករណ៍មុនៗ ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះទេ។ ទោះបីវាជាបាតុភូតថ្មីគួរសមក៏ដោយ ក៏ក្រមនេះស្នើឲ្យដាក់ទង្វើឧក្រិដ្ឋនេះជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយសារតែវាមានភាពសាហាវឃោរឃៅ និងធ្ងន់ធ្ងរហួសប្រមាណ"*[31]។

៣១. គណៈកម្មាធិការសិទ្ធិមនុស្សអន្តរជាតិ បានទាញនិយមន័យចេញពីសេចក្តីប្រកាសស្តីពីការការពារប្រឆាំងនឹងការបាត់ខ្លួនមនុស្សដោយបង្ខំ ដែលអនុម័តដោយមហាសន្និបាតនៅឆ្នាំ១៩៩២ និងអនុសញ្ញាអន្តរអាមេរិក ឆ្នាំ១៩៩៤ ស្តីពីការបាត់ខ្លួនមនុស្សដោយបង្ខំ[32]។

៣២. លិខិតុបករណ៍ពីរចុងក្រោយនេះត្រូវបានអនុម័ត ក្នុងរយៈពេល ១៣ និង ១៥ ឆ្នាំរៀងគ្នា ក្រោយយុត្តាធិការពេលវេលារបស់ អ.វ.ត.ក។ ដូច្នេះ ឧក្រិដ្ឋកម្ម *"បាត់ខ្លួនដោយបង្ខំ"* មិនស្ថិតនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះទេ។ ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ក៏មិនមានកំណត់អំពីឧក្រិដ្ឋកម្ម *"បាត់ខ្លួនដោយបង្ខំ"* នោះដែរ។

៣៣. អាស្រ័យហេតុនេះ ដោយសារគ្មានការកំណត់អំពីឧក្រិដ្ឋកម្មនេះ ក្នុងអំឡុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក និងយោងតាមគោលការណ៍អប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ អង្គជំនុំជម្រះមិន

---

[30] សេចក្តីព្រាងក្រមរបស់គណៈកម្មាធិការសិទ្ធិមនុស្សអន្តរជាតិ ទំព័រ ១២៥។

[31] សេចក្តីព្រាងក្រមរបស់គណៈកម្មាធិការសិទ្ធិមនុស្សអន្តរជាតិ ទំព័រ ១២៣។

[32] ដូចយោងខាងលើ។

អាចទទួលយកឧក្រិដ្ឋកម្មនេះ ហើយចាត់ទុកថាជា "អំពើអមនុស្សធម៌ផ្សេងទៀត" បានទេ។

## II- ច្បាប់ជាធរមានដែលអនុវត្តចំពោះបែបផែននៃការទទួលខុសត្រូវ ដែលបានកំណត់យកនៅក្នុងសំណុំរឿង ០០២/០១

### ១. ការទទួលខុសត្រូវព្រហ្មទណ្ឌផ្ទាល់ខ្លួន ក្នុងឋានៈជាអ្នកដែលបានចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម

៣៤. កម្មវត្ថុនៃផ្នែកនេះគឺសម្តៅកំណត់ព្រំដែននៃច្បាប់ដែលត្រូវអនុវត្តទៅលើសហឧក្រិដ្ឋកម្មរួម ក្នុងទម្រង់មូលដ្ឋាន។ ជាក់ស្តែង សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញាបានពន្លាតទម្រង់នៃការទទួលខុសត្រូវចំពោះសហឧក្រិដ្ឋកម្មរួម រហូតដល់បង្ហាញថា រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យគឺជាសហឧក្រិដ្ឋកម្មរួមដ៏ធំមួយ។ ការបង្ហាញនេះមានលក្ខណៈផ្ទុយនឹងច្បាប់ជាធរមាន។ មេធាវីការពារក្តីលោក ខៀវ សំផន សូមស្នើសុំឱ្យសហព្រះរាជអាជ្ញាធ្វើការកំណត់ឱ្យបានច្បាស់លាស់អំពីនយោបាយទាំងឡាយដែលអនុម័តដោយរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ហើយដែលត្រូវបានចោទប្រកាន់នៅក្នុងក្របខណ្ឌនៃរឿងក្តីបច្ចុប្បន្ន ដែលសហព្រះរាជអាជ្ញានឹងត្រូវបង្ហាញចរិតលក្ខណៈបែបឧក្រិដ្ឋកម្មនៃនយោបាយនីមួយៗនោះ។ អយ្យការក៏ត្រូវលើកបង្ហាញភ័ស្តុតាងអំពីការចូលរួមរបស់ជនជាប់ចោទទៅក្នុងការតាក់តែង និងការដាក់ចេញនូវនយោបាយនីមួយៗផងដែរ។

#### ក. ធាតុផ្សំនៃសហឧក្រិដ្ឋកម្មរួម

៣៥. នៅក្នុងសេចក្តីសម្រេចពាក់ព័ន្ធនឹងសហឧក្រិដ្ឋកម្មរួម អង្គជំនុំជម្រះបានបញ្ជាក់ថា អង្គជំនុំជម្រះនឹងមិនធ្វើការពិចារណាអំពីសហឧក្រិដ្ឋកម្មរួមដែលស្ថិតក្នុងប្រភេទទី៣ឡើយ ដោយហេតុថា សហឧក្រិដ្ឋកម្មរួមប្រភេទនេះពុំស្តែងឡើងជាគោលការណ៍ទូទៅនៃច្បាប់ដែលមាននៅចន្លោះពីឆ្នាំ ១៩៧៥ និង ១៩៧៩[33] ឡើយ។ ដូច្នេះ មានតែទម្រង់មូលដ្ឋាន និងជាប្រព័ន្ធទេ ដែលត្រូវបានយកមកអនុវត្តនៅចំពោះមុខអង្គជំនុំជម្រះនោះ។

---

33 សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសហឧក្រិដ្ឋកម្មរួម ("សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសហឧក្រិដ្ឋកម្មរួម") ឯកសារ **E100/6** ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១ កថាខណ្ឌ ២៩។

៣៦. តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គូស្លាវី និងប្រទេសរវ៉ាន់ដា បានធ្វើការកំណត់ដូចគ្នានូវធាតុផ្សំសត្យានុម័តដែលជាមូលដ្ឋានដ៏សំខាន់នៃទ្រឹស្តីសហឧក្រិដ្ឋកម្មរួម។ ផ្អែកលើយុត្តិសាស្ត្ររបស់តុលាការទាំងពីរនេះ ធាតុផ្សំសត្យានុម័ត (*Actus Reus*) តម្រូវ មានលក្ខណៈតែមួយដូចគ្នាសម្រាប់ប្រភេទទាំងបីនៃសហឧក្រិដ្ឋកម្មរួម។ នៅក្នុងសាលក្រមឌុច អង្គជំនុំជម្រះបានកំណត់ដែនអនុវត្តន៍យុត្តិសាស្ត្រទៅលើករណីនៃរឿងក្តី ទាក់ទងនឹងសហឧក្រិដ្ឋរួមនេះ។ អង្គជំនុំជម្រះបានកំណត់ថា ផែនការរួមគឺ "សំដៅដល់ការប្រព្រឹត្ត" បទឧក្រិដ្ឋណាមួយ ដែលស្ថិតនៅក្នុងដែនយុត្តាធិការរបស់អង្គជំនុំជម្រះ ឬ "ចូលរួមប្រព្រឹត្ត"[34]អំពើឧក្រិដ្ឋនោះ។ អង្គជំនុំជម្រះក៏បានលើកឡើងផងដែរថា ផែនការនេះមិនត្រូវបានបង្កើត ឬរៀបចំទុកជាមុនឡើយ៖ "*វាអាចកើតមានឡើងដោយឥតព្រៀងទុកជាមុន និងអាចត្រូវបានទាញសេចក្តីសន្និដ្ឋានពីអង្គហេតុ*"[35]។ អង្គជំនុំជម្រះក៏បានរំលឹកជាចុងក្រោយថា ចាំបាច់ត្រូវតែមានការចូលរួមរបស់ជនជាប់ចោទទៅក្នុងគោលបំណងរួម ទោះបីជា"*ការចូលរួមនេះមិនពាក់ព័ន្ធនឹងការប្រព្រឹត្តបទឧក្រិដ្ឋជាក់លាក់ណាមួយក៏ដោយ ប៉ុន្តែអាចធ្វើឡើងក្នុងទម្រង់ជាការជួយ ឬរួមចំណែកដល់ការអនុវត្តគោលបំណងរួមនេះ*"[36]។

៣៧. ពាក់ព័ន្ធនឹងធាតុផ្សំអត្តនោម័ត (*Mens Rea*) ធាតុផ្សំនេះមានការប្រែប្រួលអាស្រ័យទៅតាមប្រភេទផ្សេងៗគ្នានៃសហឧក្រិដ្ឋកម្មរួម។ សម្រាប់សហឧក្រិដ្ឋកម្មរួមក្នុងទម្រង់មូលដ្ឋាន (ប្រភេទទីមួយ) អង្គជំនុំជម្រះបានរំលឹកថា វាចាំបាច់ក្នុងការបង្ហាញថាមានសហចារីជាច្រើនរូបមានចេតនារួម ក្នុងការប្រព្រឹត្តបទឧក្រិដ្ឋកម្មជាក់លាក់ណាមួយ[37]។ ចំណែកឯសហឧក្រិដ្ឋកម្មរួមក្នុងប្រភេទទីពីរវិញ (ទម្រង់ជាប្រព័ន្ធ) គេត្រូវបង្ហាញថា ជនជាប់ចោទបានដឹងអំពីប្រព័ន្ធនៃការធ្វើទុក្ខបុកម្នេញ ហើយ

---

[34] សាលក្រមឌុច កថាខណ្ឌ ៥០៨ ; សាលដីកា *Brđanin* កថាខណ្ឌ ៣៦៤។

[35] សាលក្រមឌុច កថាខណ្ឌ ៥០៨។

[36] សាលក្រមឌុច កថាខណ្ឌ ៥០៨។

[37] សូមមើល សាលក្រមឌុច កថាខណ្ឌ ៥០៩ និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ១៥។ សូមមើលផងដែរ *រដ្ឋអាជ្ញា ទល់នឹង* Stakić, IT-97-24-A, ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦, សាលដីកា កថាខណ្ឌ ៦៥ ; *រដ្ឋអាជ្ញា ទល់នឹង* Kvočka *និងអ្នកផ្សេងទៀត* IT-98-30-/1-A, សាលដីកា ("សាលដីកា *Kvočka*") ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៥ កថាខណ្ឌ ៨២ ; *រដ្ឋអាជ្ញា ទល់នឹង* Ntakirutimana *និង* Ntakirutimana, ICTR-96-10-A និង ICTR 96-17-A, សាលដីកា ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៤ កថាខណ្ឌ ៤៦៧ ; *រដ្ឋអាជ្ញា ទល់* Vasiljević, IT-98-32-A, សាលដីកា ("សាលដីកា *Vasiljević*") ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៤ កថាខណ្ឌ ១០១។

ខ្លួនមានចេតនាជួយជ្រោមជ្រែងដល់ប្រព័ន្ធនោះ។ ជាចុងក្រោយ សហឧក្រិដ្ឋកម្មរួមក្នុងប្រភេទទីបី (ទម្រង់ទូលាយ) គេត្រូវបង្ហាញថា ជនជាប់ចោទមានចេតនាជួយជ្រោមជ្រែងដល់ការធ្វើឱ្យបានសម្រេចនូវគោលដៅឧក្រិដ្ឋកម្មដែលកំណត់ដោយក្រុម ពីព្រោះថា “*ការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម ដែលស្ថិតនៅក្រៅផែនការរួម អាចត្រូវបានទទួលយក តែក្នុងករណីដែលគេអាចរំពឹងទុកជាមុនថា ឧក្រិដ្ឋកម្មមួយនេះអាចត្រូវបានប្រព្រឹត្ត ហើយជនជាប់ចោទបានស្ម័គ្រចិត្តប្រថុយប្រថាននឹងហានិភ័យនៃឧក្រិដ្ឋកម្មនោះដោយខ្លួនឯង*”[38]។

## ខ. ភាពស៊ីចង្វាក់នៃការបែងចែករវាងទម្រង់មូលដ្ឋាន ទម្រង់ជាប្រព័ន្ធ និងទម្រង់ទូលាយ

៣៨. ការបែងចែកភាពខុសគ្នារវាងធាតុផ្សំអត្តនោម័តនៃទម្រង់មូលដ្ឋាន និងទម្រង់ទូលាយរបស់សហឧក្រិដ្ឋកម្មរួម មានរូបភាពដូចគ្នាទៅនឹងការបែងចែកលំដាប់គតិយុត្តិក្នុងស្រុក រវាងទម្រង់ផ្សេងៗនៃធាតុផ្សំអត្តនោម័ត (*Mens Rea*)។ ទន្ទឹមគ្នានេះ នីតិព្រហ្មទណ្ឌបារាំងបានធ្វើការបែងចែករវាងកំហុសដោយចេតនា (កំហុសដោយផ្ទាល់) និងកំហុសដោយអចេតនា (កំហុសជាយថាហេតុ)។ នៅក្នុងករណីទីមួយ “*ជនជាប់ចោទបានប្រព្រឹត្តដោយចេតនា ពោលគឺជនល្មើសបានធ្វើសកម្មភាពដោយចេតនា ដើម្បីសម្រេចនូវគោលដៅណាមួយ។*”[39]។ ផ្ទុយទៅវិញ “*នៅពេលដែលចារីមិនមានបំណងចង់ឱ្យកើតមានជាលទ្ធផលអាក្រក់ណាមួយអំពីអំពើល្មើសរបស់ខ្លួន ដោយខ្លួនគ្រាន់តែដឹងថាអំពើរបស់ខ្លួនអាចបង្កើតជាផលវិបាកដែលច្បាប់ហាមឃាត់ ក្នុងករណីនេះ វាជាកំហុសយថាហេតុ។*”[40]។

៣៩. ចេតនាប្រព្រឹត្តបទល្មើសរបស់ជនដែលបានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម ក្រោមទម្រង់មូលដ្ឋានត្រូវបានកំណត់តាមរយៈគោលដៅឧក្រិដ្ឋកម្មដែលជននោះចង់ធ្វើឱ្យបានសម្រេច។ ដូច្នេះ នៅពេលដែលផែនការរួមមានចរិតជាឧក្រិដ្ឋកម្ម ភ័ស្តុតាងដែលបញ្ជាក់អំពីចេតនារបស់ជនល្មើសត្រូវបានបង្ហាញតាមរយៈការចូលរួមរបស់ជនល្មើសក្នុងការសម្រេចឱ្យបាននូវគោលដៅនោះ[41]។

---

[38] សាលក្រមឧទ្ធរណ៍ កថាខណ្ឌ ៥០៩៖ ដកស្រង់សាលដីកា *Vasiljević* កថាខណ្ឌ ១០១។

[39] Yves Mayaud, *នីតិព្រហ្មទណ្ឌទូទៅ* គ្រឹះស្ថានបោះពុម្ពផ្សាយ Presses Universitaires de France (ឆ្នាំ ២០០៤) ទំព័រ ១៧៩។

[40] Bernard Bouloc, *នីតិព្រហ្មទណ្ឌទូទៅ* គ្រឹះស្ថានបោះពុម្ពផ្សាយ Dalloz (ឆ្នាំ ២០០៧) ទំព័រ ២៤៦។

[41] សាលក្រម *Blagojević* កថាខណ្ឌ ៧០៣។ អង្គជំនុំជម្រះសាលាដំបូងប្រកាសថា៖ “*ប្រភេទទីមួយតម្រូវឱ្យមានភ័ស្តុតាង*

៤០. នៅក្នុងសាលក្រម **ឌុច** ដើម្បីបង្ហាញអំពីការប្រព្រឹត្តទៅនៃសហឧក្រិដ្ឋកម្មរួមក្នុងទម្រង់មូលដ្ឋាន អង្គជំនុំជម្រះបានលើកឧទាហរណ៍អំពីផែនការមនុស្សឃាតមួយ ដែលបានរៀបចំឡើងដោយមនុស្សមួយក្រុម បើទោះបីជាពួកគេទាំងនោះដើរតួផ្សេងៗគ្នានៅក្នុងការធ្វើឲ្យបានសម្រេចនូវផែនការរួមនោះក៏ដោយ ក៏ប៉ុន្តែពួកគេសុទ្ធតែមានចេតនាក្នុងការសម្លាប់មនុស្សទាំងអស់គ្នា[42]។ នៅក្នុងឧទាហរណ៍នេះ យើងឃើញថា គោលដៅដែលគេចង់ឲ្យបានសម្រេចផែនការ និងឧក្រិដ្ឋកម្មដែលស្ថិតក្រោមយុត្តាធិការរបស់ អ.វ.ត.ក. មានលក្ខណៈច្រឡូកច្រឡំគ្នាទៅវិញទៅមក៖ ក្នុងករណីទាំងពីរនេះ វាទាក់ទងនឹងអំពើមនុស្សឃាត។ នៅក្នុងករណីនេះ ចេតនាចូលរួមអនុវត្តផែនការរួមគឺជាទង្វើឧក្រិដ្ឋ ដោយហេតុថា ផែនការរួមមានចរិតលក្ខណៈជាឧក្រិដ្ឋកម្ម។ អាចនិយាយម្យ៉ាងទៀតបានថា ដោយហេតុថាផែនការរួមមានលក្ខណៈជាឧក្រិដ្ឋកម្ម ដូច្នេះគេអាចសន្និដ្ឋានបានថា រាល់ទង្វើទាំងឡាយរបស់អ្នកដែលបានចូលរួម ក្នុងការធ្វើឲ្យបានសម្រេចនូវផែនការរួម ពិតជាបង្កប់នូវឆន្ទៈឧក្រិដ្ឋកម្មយ៉ាងជាក់ច្បាស់។ ជាមួយគ្នានេះ នៅក្នុងទម្រង់ទីមួយនៃសហឧក្រិដ្ឋកម្មរួម រាល់ទង្វើទាំងឡាយដែលមានគោលដៅធ្វើឲ្យបានសម្រេចនូវផែនការមនុស្សឃាត សបញ្ជាក់យ៉ាងសមហេតុសមផលអំពីចេតនាប្រព្រឹត្ត បទមនុស្សឃាតរបស់ជនដែលបានចូលរួមទៅក្នុងផែនការនោះ។

៤១. ធាតុផ្សំអត្តនោម័តនៅក្នុងប្រភេទទីពីរនៃសហឧក្រិដ្ឋកម្មរួម (ទម្រង់ជាប្រព័ន្ធ) ក៏ស្ថិតនៅក្នុងប្រភេទកំហុសដោយផ្ទាល់ដែរ៖ គេត្រូវបង្ហាញថា ជនជាប់ចោទបានដឹងដោយខ្លួនឯងផ្ទាល់អំពីប្រព័ន្ធនៃការធ្វើទុក្ខបុកម្នេញ ហើយខ្លួនមានចេតនាជួយជ្រោមជ្រែងដល់ការអនុវត្តប្រព័ន្ធនោះ។ ទម្រង់នៃការចូលរួមនេះ ត្រូវបានប្រើប្រាស់ដើម្បីបង្ហាញអំពីការចូលរួមដោយផ្ទាល់របស់ជនជាប់ចោទទៅក្នុងការអនុវត្តប្រព័ន្ធនៃការធ្វើទុក្ខបុកម្នេញ ឧទាហរណ៍ដូចជាជំរំជាដើម ដែលនៅក្នុងប្រព័ន្ធនោះ មានការប្រព្រឹត្តជាប្រចាំ និងជាប្រព័ន្ធនូវបទល្មើសទាំងឡាយដែលស្ថិតក្រោមយុត្តាធិការរបស់តុលាការដែលពាក់ព័ន្ធ។ ទម្រង់នៃការចូលរួមនេះ ដែលអាចឲ្យគេចាត់ទុករបបកម្ពុជាប្រជាធិបតេយ្យទាំងមូលថាជា "ប្រព័ន្ធនៃការធ្វើទុក្ខបុកម្នេញ" មិនត្រូវយកមកអនុវត្តនៅក្នុងសំណុំរឿងបច្ចុប្បន្ននេះទេ។

---

*បញ្ជាក់ថា អ្នកចូលរួមទាំងអស់មានចេតនាប្រព្រឹត្តបទឧក្រិដ្ឋដូចគ្នា។ ត្រូវបង្ហាញឲ្យឃើញថា* ***ជនជាប់ចោទបានចូលរួមប្រព្រឹត្តដោយចេតនា និងចង់ឲ្យកើតបទឧក្រិដ្ឋ។"។***

[42] សាលក្រមឌុច កថាខណ្ឌ ៥០៧។

៤២. ប្រភេទទីបីនៃសហឧក្រិដ្ឋកម្មរួមអាចឲ្យគេទម្លាក់ការទទួលខុសត្រូវ ចំពោះផលវិបាកអាក្រក់នានាដែលកើតចេញមកអំពីការធ្វើឲ្យសម្រេចនូវផែនការរួម ទៅលើជនដែលបានចូលរួមក្នុងការអនុវត្តផែនការរួមនោះ ទោះបីជាពួកគេមិនបានរំពឹងទុកជាមុនថានឹងធ្វើឲ្យកើតមាននូវផលវិបាកនោះក៏ដោយ ប៉ុន្តែពួកគេអាចដឹងជាមុនបានថា ផលវិបាកនោះនឹងអាចកើតមានឡើងបាន។ ដូច្នេះ ពុំមានលក្ខណៈសម្គាល់ច្បាស់លាស់ រវាងគោលដៅដែលចង់បាន និងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នោះទេ។ ផ្ទុយអំពីទម្រង់ទីមួយនៃសហឧក្រិដ្ឋកម្មរួម គេមិនអាចទាញសេចក្តីសន្និដ្ឋានយ៉ាងសមហេតុសមផលបានថាជនជាប់ចោទបានចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម ក្នុងចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មទាំងឡាយដែលស្ថិតនៅក្នុងផែនការរួមនោះទេ ដោយហេតុថា ជនដែលបានចូលរួមទៅក្នុងផែនការរួមនោះ មិនមានគោលដៅប្រព្រឹត្តនូវឧក្រិដ្ឋកម្មទាំងនោះទេ។ ដូច្នេះ ប្រសិនណាជាពុំមានលក្ខណៈសម្គាល់រវាងគោលដៅដែលចង់បាន និងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តទេ ការកំណត់នូវធាតុផ្សំអត្តនោម័តគ្មានអ្វីក្រៅតែអំពីកំហុសជាយថាហេតុនោះឡើយ។ គេអាចនិយាយបានម្យ៉ាងទៀតថា ប្រសិនណាជាគោលដៅដែលចង់បាន មិនបានស្តែងឡើងជាការប្រព្រឹត្តបទល្មើសទេ ដូច្នេះមានតែប្រភេទទីបីនៃសហឧក្រិដ្ឋកម្មរួមទេ ដែលអាចអនុវត្តបាន។

៤៣. ជាក់ស្តែង នៅក្នុងសេចក្តីសម្រេចពាក់ព័ន្ធនឹងភាពដែលអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួម អង្គជំនុំជម្រះ ដូចគ្នាទៅនឹងអង្គបុរេជំនុំជម្រះ[43]ដែរ បានសម្រេចថា សហឧក្រិដ្ឋកម្មរួមក្នុងប្រភេទទីបី (ទម្រង់ទូលាយ) *"នឹងមិនអាចត្រូវបានចាត់ទុកថាបានបង្កើតជាគោលការណ៍ទូទៅនៃច្បាប់នៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ទេ"*[44]។ ដូច្នេះ មានតែប្រភេទទីមួយនៃចេតនាប្រព្រឹត្តបទល្មើស (ចេតនាផ្ទាល់) ទេ ដែលអាចត្រូវបានប្រើប្រាស់ដើម្បីកំណត់នូវចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មរបស់ជនដែលបានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម ក្នុងក្របខណ្ឌនៃសំណុំរឿង ០០២/០១។ ជាក់ស្តែង ដោយផ្អែកលើហេតុផលដូចបានបញ្ជាក់ខាងលើ វាជាការចាំបាច់ដែលត្រូវបង្ហាញថា កម្មវត្ថុរួមមានចរិតជាឧក្រិដ្ឋកម្ម មុននឹងធ្វើការសន្និដ្ឋានថា ជនដែលបានចូលរួមទៅក្នុងកម្មវត្ថុរួមនោះ ពិតជាមានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្ម (កំហុសផ្ទាល់) មែន។ ដូច្នេះ វាជាការចាំបាច់ដែលត្រូវបញ្ជាក់ឲ្យបាន

---

[43] សាលដីការបស់អង្គជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ ឯកសារ **D97/15/9** កថាខណ្ឌ ៨៧។

[44] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ២៩។

ច្បាស់ អំពីព្រំដែននៃគោលដៅរបស់សហឧក្រិដ្ឋកម្មរួមដែលត្រូវបានចោទប្រកាន់ក្នុងសំណុំរឿង 00២/ 0១។

## គ. __ការកំណត់ចរិតលក្ខណៈនៃគោលដៅឧក្រិដ្ឋកម្មក្នុងសំណុំរឿង 00២/0១__

៤៤. ពាក់ព័ន្ធនឹងសារជាតិនៃផែនការរួម សេចក្តីសម្រេចបញ្ជូនរឿងទៅជំនុំជម្រះបានលើកឡើងថា៖ *"ផែនការរួមរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាប្រជាធិបតេយ្យ គឺធ្វើឲ្យសម្រេចបាននូវបដិវត្តន៍សង្គមនិយមឆាប់រហ័សមួយនៅកម្ពុជា តាម "ជំហានមហាលោតផ្លោះ" និងការពារប្រទេសប្រឆាំងទៅនឹងសត្រូវទាំងខាងក្នុង និងខាងក្រៅ តាមគ្រប់មធ្យោបាយចាំបាច់។ ផែនការរួមនេះពុំមែនមានលក្ខណៈឧក្រិដ្ឋទាំងស្រុងនោះទេ ប៉ុន្តែការធ្វើឲ្យបានសម្រេចផែនការរួមនេះរួមមាន ជាការប្រព្រឹត្តនូវឧក្រិដ្ឋកម្មដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក. ឬក៏ជាការជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះ។"*[45]។

៤៥. ដូចគ្នាផងដែរ *"ដើម្បីសម្រេចនូវផែនការរួមនេះ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានកំណត់យកគោលនយោបាយ ៥ យ៉ាង ដូចមានរៀបរាប់ខាងក្រោម ដែលការដាក់ឲ្យអនុវត្តនូវគោលនយោបាយទាំងនេះស្តែងឡើងជាការប្រព្រឹត្តនូវឧក្រិដ្ឋកម្ម ឬក៏ជាការជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តឧក្រិដ្ឋកម្ម។ "*[46]។ នៅក្នុងសំណុំរឿង 00២ នយោបាយទាំង ៥ នេះ មានដូចតទៅ៖ ១). ការជម្លៀសប្រជាជនជាច្រើនលើកច្រើនសាចេញពីទីក្រុង និងពីតំបន់ជនបទមួយទៅកាន់តំបន់ជនបទផ្សេងៗទៀត។ ២). ការបង្កើត និងការដាក់ឲ្យដំណើរការសហករណ៍ និងជំរំធ្វើការងារ។ ៣). ការអប់រំ "សមាសភាពមិនល្អ" និងការកម្ទេច "ខ្មាំង" ទាំងខាងក្នុង និងខាងក្រៅបក្ស។ ៤). ការចាត់វិធានការដោយឡែកទៅលើក្រុមមនុស្សជាក់លាក់មួយចំនួន ជាពិសេសជនជាតិចាម វៀតណាម ក្រុមពុទ្ធសាសនិកជន និងអតីតមន្ត្រី (មន្ត្រីរាជការ យោធា និងក្រុមគ្រួសាររបស់ពួកគេ) នៃរបបសាធារណរដ្ឋខ្មែរ។ និង ៥). ការរិតត្បិតសេរីភាពអាពាហ៍ពិពាហ៍[47]។

---

[45] ដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២0១0 ឯកសារ **D427** កថាខណ្ឌ ១៥២៤។

[46] ដូចខាងលើ។

[47] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥២៥។

៤៦. នៅក្នុងសេចក្តីសម្រេចពាក់ព័ន្ធនឹងភាពដែលអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួម អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា៖ *"ទោះបីជាគោលបំណងនៃផែនការរួមពុំមែនមានលក្ខណៈឧក្រិដ្ឋទាំងស្រុងក៏ដោយ តែវាបានបញ្ជាក់ច្បាស់ថា ការអនុវត្តផែនការរួមនោះគឺពាក់ព័ន្ធនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក.។[48]"* ។ អង្គជំនុំជម្រះបានប្រកាសថា៖ *"ដើម្បីកំណត់ការទទួលខុសត្រូវរបស់ជនជាប់ចោទម្នាក់ ក្នុងឋានៈជាអ្នកដែលបានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម គេត្រូវបង្ហាញថា ជននោះបានចូលរួមក្នុងបែបផែនមួយ ទៅក្នុងផែនការរួម ដែលជាការប្រព្រឹត្តនូវឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការដែលពាក់ព័ន្ធ មិនថាជននោះបានប្រព្រឹត្តបទល្មើសតែមួយក្នុងចំណោមបទល្មើសទាំងនោះ ឬក៏គ្រាន់តែបានជួយជ្រោមជ្រែង ឬរួមចំណែកដល់ការធ្វើឲ្យបានសម្រេចនូវផែនការរួមនោះឡើយ។"*[49]។

៤៧. ផ្អែកលើរឿងក្តី រដ្ឋអាជ្ញា ប្តឹងទល់នឹង *Brima* និងអ្នកផ្សេងទៀត[50] និងរឿងក្តី រដ្ឋអាជ្ញាប្តឹង ទល់នឹង *Kvočka*[51] អង្គជំនុំជម្រះបានប្រកាសថា *"យុត្តិសាស្ត្ររបស់តុលាការអន្តរជាតិបានសម្រេចយ៉ាងស៊ីសង្វាក់គ្នាថា ផែនការរួមដែលបានបង្កើតជាសហឧក្រិដ្ឋកម្មរួមពុំចាំបាច់មានលក្ខណៈឧក្រិដ្ឋនោះទេ ល្គឹកណាបទល្មើសត្រូវបានពិចារណាថាជាមធ្យោបាយមួយក្នុងការនាំឲ្យផែនការរួមសម្រេចចេញជាលទ្ធផលនោះ។"*[52]។

៤៨. អំណះអំណាងរបស់អង្គជំនុំជម្រះអាចត្រូវបានមើលឃើញថាមានលក្ខណៈមិនច្បាស់លាស់ ហើយគួរតែត្រូវធ្វើការបញ្ជាក់ឲ្យច្បាស់លាស់។ ជាក់ស្តែង ក្នុងចំណោមករណីទាំងពីរ មានករណីមួយ៖ ឬមួយគោលដៅបង្កប់[53]ដោយការប្រព្រឹត្តឧក្រិដ្ឋកម្ម ហើយក្នុងករណីនេះគោលដៅមានលក្ខណៈជា

---

[48] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ១៩។

[49] ដូចខាងលើ។

[50] *រដ្ឋអាជ្ញា ទល់នឹង Brima និងអ្នកផ្សេងទៀត* SCSL-2004-16-A, សាលដីកា ("សាលដីកា *Brima*") ចុះថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០០៨។

[51] សាលដីកា *Kvočka* ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៥។

[52] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ១៧។

[53] វចនានុក្រម Larousse កំណត់និយមន័យកិរិយាសព្ទ "បង្កប់ (impliquer)" ថា៖ "សន្មត មានជាចាំបាច់នូវអត្ថិភាពនៃអ្វីមួយផ្សេងទៀត មានផលវិបាកចាំបាច់ សមហេតុផល។"

ឧក្រិដ្ឋកម្ម ឬក៏គ្រោង[54] ប្រព្រឹត្តឧក្រិដ្ឋកម្មនៅក្នុងអំឡុងពេលនៃការដាក់ចេញនូវផែនការនយោបាយមួយដែលមានលក្ខណៈស្របច្បាប់នោះ។

៤៩. នៅក្នុងករណីទីមួយ យើងសន្មតថាផែនការដែលដាក់ចេញដោយមេដឹកនាំកម្ពុជាប្រជាធិបតេយ្យក្នុងការបង្កើតឡើងនៅកម្ពុជានូវរដ្ឋកុម្មុយនីស្តមួយ តម្រូវឲ្យមានការប្រព្រឹត្តបទឧក្រិដ្ឋកម្ម មានន័យថា ការចូលរួមក្នុងការកសាងរបបនេះឡើង គឺជាទង្វើមួយដែលមានលក្ខណៈឧក្រិដ្ឋសុទ្ធសាធ។ ជាក់ស្តែង ទស្សនៈនេះគឺចង់ធ្វើការកំណត់ឲ្យបានច្បាស់រវាងគោលដៅដែលគេចង់បាន និងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត៖ ដូច្នេះ គោលដៅដែលផែនការនយោបាយចង់ឲ្យបានសម្រេច គឺការប្រព្រឹត្តឧក្រិដ្ឋកម្ម។ នៅក្នុងករណីនេះ ដោយហេតុថាផែនការក្នុងការកសាងកុម្មុយនីស្តមួយ នៅកម្ពុជាមានលក្ខណៈជាឧក្រិដ្ឋកម្ម ដូច្នេះរាល់ទង្វើទាំងឡាយរបស់អ្នកដែលបានចូលរួមក្នុងការធ្វើឲ្យរបបកម្ពុជាប្រជាធិបតេយ្យលេចចេញជារូបរាង អាចឲ្យគេកំណត់បាននូវចេតនាប្រព្រឹត្ត ឧក្រិដ្ឋកម្មដែលកើតមានឡើងនៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩។ យើងឃើញថា ទស្សនៈនេះពុំមានលក្ខណៈសមស្របទេ ដោយហេតុថាវាបានធ្វើឲ្យរួមខ្ចី ក្នុងការដែលបង្ហាញអំពីចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មតែចំពោះសមាជិកនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យតែមួយនោះ។ ដោយយល់ឃើញដូច្នេះ ទស្សនៈនេះបានចាត់ទុករាល់ការជាប់ពាក់ព័ន្ធជាមួយរបបកម្ពុជាប្រជាធិបតេយ្យ សុទ្ធសឹងជាឧក្រិដ្ឋកម្ម ហើយអាចនឹងបង្កើតឲ្យមានជាស្ថានភាពមួយ ដូចដែលតុលាការនៅនូរ៉ាំប៊ែរ (Nuremberg) បានហៅថាជា "បទល្មើសអង្គការ" ពោលគឺជាបទល្មើសមួយដែលសម្តៅទៅលើស្ថានភាពដែលឯកត្តបុគ្គលត្រូវបានភ្ជាប់ទៅនឹងស្ថាប័ន ឬក្រុមឧក្រិដ្ឋជនណាមួយ[55]។ សញ្ញាណនេះដែលមិនធ្លាប់មានចែងនៅក្នុងលក្ខន្តិកៈនៃតុលាការពិសេស (*ad hoc*) ណាមួយនោះ ត្រូវបានបោះបង់ចោលដោយនីតិព្រហ្មទណ្ឌអន្តរជាតិសម័យបច្ចុប្បន្ន។

៥០. នៅក្នុងករណីទីពីរ ប្រសិនណាជាគេចាត់ទុកថា គោលដៅក្នុងការកសាងរដ្ឋកុម្មុយនីស្តមួយនៅកម្ពុជា (ការបង្កើតនូវកម្ពុជាប្រជាធិបតេយ្យ) ជារឿងមួយដែលស្របច្បាប់ នោះគេអាចនឹកឃើញដល់ដំណោះស្រាយតាមផ្លូវច្បាប់ចំនួនពីរ។

---

[54] វចនានុក្រម Larousse កំណត់និយមន័យកិរិយាសព្ទ "គ្រោង (envisager)" ថា៖ "គ្រោងរៀបចំគម្រោងមួយ ពិនិត្យពិចារណាគិតគូររឿងអ្វីមួយ"។

[55] សូមមើលមាត្រា ៩ ដល់មាត្រា ១១ នៃលក្ខន្តិកៈតុលាការ Nuremberg។

៥១. ដំណោះស្រាយទីមួយ គឺថា៖ ដោយមិនគិតថាគោលដៅរួមផ្ទាល់មានលក្ខណៈជាឧក្រិដ្ឋកម្មឬគ្មាននោះទេ ប៉ុន្តែវាជារឿងដែលអាចដឹងជាមុនបានថាអាចនឹងមានការប្រព្រឹត្តឧក្រិដ្ឋកម្មនៅក្នុងដំណាក់កាលនៃការស្ថាបនារបបកម្ពុជាប្រជាធិបតេយ្យនោះ ហើយជនជាប់ចោទក៏បានទទួលយកហានីភ័យនេះ ដោយបានចូលរួមទៅក្នុងការស្ថាបនារបបនេះទៀត។ ដំណោះស្រាយនេះមិនមានលក្ខណៈខុសឆ្គងអ្វីតាមផ្លូវច្បាប់នោះឡើយ ប៉ុន្តែវាបានឆ្លើយតបទៅនឹងសហឧក្រិដ្ឋកម្មរួមក្នុងទម្រង់ទូលាយ។ ដោយឡែក បែបផែននៃការទទួលខុសត្រូវនេះមិនអាចត្រូវបានចាត់ទុកថាបានបង្កើតជាគោលការណ៍ទូទៅនៃច្បាប់នៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ទេ។ អង្គជំនុំជម្រះបានច្រានចោលដំណោះស្រាយនេះ ហើយមិនអាចទទួលយកដំណោះស្រាយនេះដោយមិនបានរំលោភលើគោលការនីត្យានុកូលភាពបានឡើយ។

៥២. ដំណោះស្រាយទីពីរគឺធ្វើការបង្ហាញថា ការកសាងរដ្ឋកុម្មុយនីស្តមួយនៅកម្ពុជា តាមរយៈកម្ពុជាប្រជាធិបតេយ្យ មានកម្មវត្ថុស្របច្បាប់ ទោះបីជាមាននយោបាយមួយចំនួនដែលបានដាក់ចេញដោយរបបនោះ អាចត្រូវបានគេចាត់ទុកថាមានលក្ខណៈជាឧក្រិដ្ឋកម្មក៏ដោយ។ នៅក្នុងករណីនេះ ដោយហេតុថា កម្មវត្ថុនៃការបង្កើតកម្ពុជាប្រជាធិបតេយ្យពុំមានលក្ខណៈជាឧក្រិដ្ឋកម្ម ពុំមែនឲ្យតែរាល់ទង្វើនៃការចូលរួមយ៉ាងសាមញ្ញទៅក្នុងរបបនោះ ពិតជាអាចសបញ្ជាក់អំពីចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មណាមួយនោះទេ។ មានតែទស្សនៈដែលយល់ឃើញផ្ទុយអំពីការចូលរួមជាលក្ខណៈបុគ្គលដោយផ្ទាល់ទៅក្នុងនយោបាយ ដែលមានចរិតជាឧក្រិដ្ឋកម្មដូចដែលបានចោទប្រកាន់ទេ ទើបអាចកំណត់បានថាជនល្មើសពិតជាមានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មមែននោះ។

៥៣. ជាក់ស្តែង ផ្ទុយអំពីការវិភាគបែបបញ្ចិតបញ្ចៀងដែលអង្គជំនុំជម្រះបានធ្វើនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនពាក់ព័ន្ធនឹងភាពដែលអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួម មានតែដំណោះស្រាយចុងក្រោយនេះទេ ដែលត្រូវបានប្រកាន់យកដោយអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គូស្លាវី និងតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន នោះ។

៥៤. នៅក្នុងបណ្តឹងឧទ្ធរណ៍នៃរឿងក្តី *Brima និងអ្នកផ្សេងទៀត* រដ្ឋអាជ្ញាបានរិះគន់សាលក្រមដែលបានសម្រេចដោយយល់ច្រឡំរវាងគោលបំណងចុងក្រោយរបស់សហឧក្រិដ្ឋកម្មរួម ទៅនឹងគោលដៅ

ឧក្រិដ្ឋកម្ម[56]។ បន្ទាប់មក អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានគាំទ្រការរិះគន់របស់រដ្ឋអាជ្ញា និងបានកែប្រែសាលក្រម។ ធ្វើដូច្នេះ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានយល់ស្របថា ចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មពុំមែនត្រូវបានកំណត់ដោយផ្អែកទៅលើ "គោលបំណងចុងក្រោយ" នោះទេ ប៉ុន្តែគឺផ្អែកទៅលើ "មធ្យោបាយឧក្រិដ្ឋ" ដែលត្រូវបានប្រើដើម្បីសម្រេចនូវគោលដៅនោះ៖ "*ទោះបីជាយើងចាត់ទុកគោលបំណងក្នុងការច្បាមយក ឬកាន់កាប់អំណាចនយោបាយនៅសេរ៉ាឡេអូន និងធ្វើការកាន់កាប់ទៅលើដែនដីទាំងមូល ថាជាឧក្រិដ្ឋកម្មដូចមានចែងក្នុងលក្ខន្តិកៈ ក៏ដោយ* ***ក៏ករណីនេះវាពុំដូចគ្នាទេចំពោះទង្វើទាំងឡាយដែលត្រូវបានចាត់ទុកថាជាមធ្យោបាយ ដើម្បីសម្រេចនូវគោលបំណងនេះ*** *ហើយដែលទង្វើទាំងនោះក៏ត្រូវបានចាត់ទុកថាជាឧក្រិដ្ឋកម្មផ្អែក តាមបទបញ្ញត្តិនៃលក្ខន្តិកៈនោះ*"[57]។ គួរឲ្យងឿងឆ្ងល់បំផុតនោះ ផ្នែកចុងក្រោយនៃឃ្លានេះបាន បាត់ចេញពីឯកសារយោងដែលប្រើដោយអង្គជំនុំជម្រះ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនពាក់ព័ន្ធនឹង ភាពដែលអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួម។

៥៥. ដូចគ្នានេះផងដែរ នៅក្នុងសាលដីកា *Kvočka* អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី បានទទួលស្គាល់អំណះអំណាងរបស់រដ្ឋអាជ្ញា ដែលថា "*ជនជាប់ចោទបានចូលរួមក្នុងផែនការរួម ពោលគឺផែនការបង្កើតរដ្ឋស៊ែប (Serbe) នៅអតីតយូហ្គោស្លាវី ហើយដែលពួកគេបានជួយជ្រោមជ្រែងក្នុងការធ្វើឲ្យបានសម្រេចដល់ផែនការនេះ ដោយបានសម្លាប់ក្រុមមូស្លីម និងជនជាតិក្រូអាត* "។ ជាថ្មីម្តងទៀត ផ្នែកចុងក្រោយនៃឃ្លានេះបានបាត់ចេញពីឯកសារយោងដែលប្រើដោយអង្គជំនុំជម្រះ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ពាក់ព័ន្ធនឹងភាពដែលអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួម។

៥៦. គេអាចបន្ថែមបានថា និន្នាការដូចគ្នានេះត្រូវបានប្រកាន់យកនៅក្នុងសំណុំរឿង *Haradinaj* ។ មានការចោទប្រកាន់ចំពោះជនជាប់ចោទថាបានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម ដែលមានគោលដៅ *អនុញ្ញាតឲ្យកងទ័ពរំដោះកូសូវ៉ូធ្វើការកាន់កាប់ទាំងស្រុងទៅលើតំបន់ប្រតិបត្តិការ Dukagjin* ***ដោយធ្វើការបណ្តេញដោយខុសច្បាប់ និងដោយធ្វើទុក្ខបុកម្នេញទៅលើជនស៊ីវិលស៊ែប ព្រមទាំងជនស៊ីវិលអាល់បានី និងរ៉ូម/ជនជាតិអេស៊ីប នៅកូសូវ៉ូ និងជនស៊ីវិលដទៃទៀតដែលបានសហការ***

---

[56] សាលដីកា *Brima* កថាខណ្ឌ ៨៤។

[57] ដូចខាងលើ កថាខណ្ឌ ៧០។

*ឬត្រូវបានសង្ស័យថា បានសហការជាមួយកងកម្លាំងស៊ែប ឬត្រូវបានសង្ស័យថាមិនបានគាំទ្រដល់កងកម្លាំងរំដោះកូសូវ៉ូ។*'[58]។

៥៧. នៅក្នុងរឿងក្ដីទាំងបីនេះ មានការបែងចែកយ៉ាងច្បាស់លាស់រវាង "គោលបំណងចុងក្រោយ" និងគោលដៅឧក្រិដ្ឋកម្មរួម។ តាមរយៈនោះ ធាតុផ្សំដើម្បីបង្ហាញអំពីចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មរបស់ជនដែលបានចូលរួមទៅក្នុងសហឧក្រិដ្ឋកម្មរួម ពុំមែនជាការចូលរួមផ្នែកបញ្ញារបស់ជននោះទៅក្នុងគោលដៅចុងក្រោយទេ ប៉ុន្តែគឺការចូលរួមជាក់ស្ដែងរបស់ពួកគេទៅក្នុងការផ្ដល់មធ្យោបាយប្រព្រឹត្តឧក្រិដ្ឋកម្មដើម្បីធ្វើឲ្យបានសម្រេចនូវគោលដៅចុងក្រោយឯណោះទៅវិញទេ។ ដំណោះស្រាយផ្ទុយមួយ បានបង្កើតជាលទ្ធផលមួយដែលមានលក្ខណៈមិនសមស្រប៖ រាល់ទង្វើរបស់ជនទាំងឡាយណា ដែលមានគោលដៅជា "ការបង្កើតរដ្ឋស៊ែប" "ធ្វើការកាន់កាប់ទៅលើដែនដីសេរ៉ាឡេអូន" ឬ "ធ្វើការកាន់កាប់ទៅលើតំបន់ប្រតិបត្តិការ *Dukagjin*" អាចឲ្យគេកំណត់បានអំពីអត្ថិភាពនៃចេតនាប្រព្រឹត្តឧក្រិដ្ឋកម្ម និងការកែប្រែទៅជាបទឧក្រិដ្ឋនូវគោលបំណងទាំងឡាយដែលត្រូវបានទទួលស្គាល់ថាស្របច្បាប់ក្នុងនីតិអន្តរជាតិសាធារណៈ។ នៅខណៈដែលនីតិអន្តរជាតិមិនបានចាត់ទុកថាជាបទឧក្រិដ្ឋនូវរាល់ទម្រង់ណាមួយនៃអង្គការចាត់តាំងនយោបាយក្នុងប្រទេស នោះដំណោះស្រាយដែលប្រកាន់យកដោយតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី មិនត្រូវមានលក្ខណៈខុសគ្នាទេនៅក្នុងក្របខណ្ឌនៃសំណុំរឿង ០០២/០១។

## ឃ. បន្ទុកនៃភស្តុតាងសម្រាប់សហព្រះរាជអាជ្ញានៅក្នុងសំណុំរឿង ០០២/០១

៥៨. ផ្អែកលើអំណះអំណាងដូចបានលើកឡើងខាងលើ អត្ថិភាពនៃចេតនាប្រព្រឹត្តឧក្រិដ្ឋកម្ម (ក្នុងអត្ថន័យច្បាប់បានសេចក្ដីថា ជាចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មដូចមានចែងក្នុងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក.) មិនអាចត្រូវបានកំណត់ដោយផ្អែកតែទៅលើចេតនាក្នុងការធ្វើបដិវត្តន៍នយោបាយ សង្គមនិយមនៅប្រទេសកម្ពុជានោះទេ។ ហេតុដូច្នេះហើយបានជាសហព្រះរាជអាជ្ញាត្រូវធ្វើការបង្ហាញអំពីការចូលរួមជាក់ស្ដែងរបស់ជនជាប់ចោទទៅក្នុងការតាក់តែង និងអនុវត្តនូវនយោបាយនីមួយៗ ដូចមានចែងក្នុងកថាខណ្ឌ ១៥២៥ នៃដីកាដំណោះស្រាយ។

[58] *រដ្ឋអាជ្ញា ទល់នឹង Haradinaj និងអ្នកផ្សេងទៀត* IT-04-84, សាលក្រម ចុះថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០០៨ កថាខណ្ឌ ៤៧០។

## ២. ការទទួលខុសត្រូវព្រហ្មទណ្ឌផ្ទាល់ខ្លួនក្នុងឋានៈជាជនសមគំនិត (ការផ្តល់ជំនួយ និងការលើកទឹកចិត្ត)

### ក. ធាតុផ្សំសត្យានុម័ត

៥៩. អំពើមានពិរុទ្ធ (*Actus Reus*) នៃបទសមគំនិតមានធាតុផ្សំចំនួនពីរ៖ ធាតុផ្សំទីមួយ ជនជាប់ចោទត្រូវតែបានផ្តល់នូវជំនួយដល់ ឬបានលើកទឹកចិត្តចារីដែលដល់ក្នុងការប្រព្រឹត្តបទល្មើស[59]។ ម្យ៉ាងទៀត ការផ្តល់ជំនួយនេះត្រូវតែបង្កើតនូវផលវិបាកជាសំខាន់ចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្ម[60]។

#### i. ធាតុផ្សំសត្យានុម័តទីមួយ៖ អំពើវិជ្ជមាន

៦០. នៅក្នុងសាលក្រម **ឌុច** អង្គជំនុំជម្រះបានសម្រេចថា អំពើទាំងឡាយដែលបានកំណត់នៅក្នុងបែបផែននៃការទទួលខុសត្រូវតាមប្រព័ន្ធច្បាប់អង់គ្លូ-សាក់សុង ពាក្យ "ជួយ និងលើកទឹកចិត្ត" ផ្ទុះបញ្ចាំងកាន់តែច្បាស់អំពី "លក្ខណៈពិតប្រាកដ" នៃបែបផែននៃការទទួលខុសត្រូវនេះ ជាងសញ្ញាណនៃពាក្យ "សមគំនិត" ក្នុងប្រព័ន្ធច្បាប់បែបបារាំង ដោយហេតុថាពាក្យនេះអាចគ្របដណ្តប់អំពើកាន់តែទូលាយជាង[61]។ ដោយឡែក គោលការណ៍នីត្យានុកូលភាពតម្រូវថា អង្គជំនុំជម្រះត្រូវធ្វើការបកស្រាយបទបញ្ញត្តិនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ដោយផ្អែកលើបទបញ្ញត្តិដែលស្ថិតនៅជាធរមាននាសម័យកាលដែលអង្គហេតុកើតមានឡើង ពោលគឺបទបញ្ញត្តិនៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ១៩៥៦ ដែលក្រមនេះបានទទួលឥទ្ធិពលពីប្រព័ន្ធច្បាប់របស់បារាំងនោះ។

៦១. នៅក្នុងប្រព័ន្ធច្បាប់បែបបារាំង អំពើសមគំនិត គឺជាអំពើវិជ្ជមាន។ មាត្រា ៨៣ នៃក្រមព្រហ្មទណ្ឌ

---

[59] សូមមើល *រដ្ឋអាជ្ញា ទល់នឹង* Simić, IT-95-9-A, សាលក្រម ("សាលក្រម *Simić*") ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៦ កថាខណ្ឌ ៨៥ ; សាលដីកា *Blaskić* កថាខណ្ឌ ៤៦ ; សាលដីកា *Vasiljević* កថាខណ្ឌ ១០២។

[60] សូមមើល សាលក្រម *Simić* កថាខណ្ឌ ៨៥ ; *រដ្ឋអាជ្ញា ទល់នឹង* Blaskić, IT-95-14-T, ថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០០០ សាលក្រម ("សាលក្រម *Blaskić*") កថាខណ្ឌ ២៨៤ ; សាលដីកា *Blaskić* កថាខណ្ឌ ៤៦ ; សាលដីកា *Vasiljević* កថាខណ្ឌ ១០២។

[61] សាលក្រមឌុច កថាខណ្ឌ ៥៣២។

កម្ពុជា ឆ្នាំ ១៩៥៦ ក៏ដូចជាមាត្រា ១២១-៧ នៃក្រមព្រហ្មទណ្ឌបារាំងថ្មី ដែលចែងអំពីបទសមគំនិត បានកំណត់តែអំពីទង្វើសកម្មប៉ុណ្ណោះ។ ហេតុដូច្នេះហើយ នៅក្នុងគោលគំនិតនៃប្រព័ន្ធច្បាប់បែបបារាំង ដែលពាក់ព័ន្ធនឹងបែបផែននៃការទទួលខុសត្រូវប្រភេទនេះ ជនទាំងឡាយដែលគ្រាន់តែជាអ្នកតាមដានមើលឧក្រិដ្ឋកម្ម ហើយមិនបានទប់ស្កាត់ការប្រព្រឹត្តឧក្រិដ្ឋកម្មនោះទេ មិនអាចត្រូវបានចាត់ទុកថាជាជនសមគំនិតឡើយ[62]។ ការណ៍ដែលជនណាម្នាក់គ្រាន់តែដឹងអំពីសកម្មភាពបទល្មើស ពុំត្រូវបានចាត់ទុកថាជាអំពើសមគំនិតដែលត្រូវផ្តន្ទាទោសនោះទេ។ ទង្វើនៃការលើកទឹកចិត្ត ពុំអាចត្រូវបានចាត់ទុកថាជាការសមគំនិតឡើយ៖ "*គេពុំអាចប្រព្រឹត្តបទសមគំនិត ដោយទង្វើអកម្មនោះឡើយ*"[63]។

៦២. តុលាការពិសេសនានា (*ad hoc*) បានពិភាក្សាលើសំណួរដែលថា តើទង្វើអកម្មអាចត្រូវបានចាត់ទុកថា ជាអំពើសមគំនិតដែរឬទេ? អង្គជំនុំជម្រះមួយចំនួននៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា បានផ្តល់នូវទស្សនៈយល់ឃើញរបស់ខ្លួនថា ជនជាប់ចោទម្នាក់អាចទទួលខុសត្រូវព្រហ្មទណ្ឌបាន ប្រសិនណាជាជននោះ មានកាតព្វកិច្ចត្រូវបំពេញ ប៉ុន្តែខ្លួនបែជាអាក់ខានមិនបានបំពេញ[64]។ ដោយទទួលបានការរិះគន់ពីសំណាក់ទ្រឹស្តីច្បាប់[65] យុត្តិសាស្ត្រមួយនេះមានលក្ខណៈផ្ទុយគ្នាទាំងស្រុងទៅនឹងទស្សនាទាននៃ ប្រព័ន្ធច្បាប់បែបបារាំង ហើយបើផ្អែកលើគោលការណ៍នីត្យានុកូលភាព យុត្តិសាស្ត្រនេះនឹងមិនគួរត្រូវបានទទួលយកដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងក្របខ័ណ្ឌនៃសំណុំរឿងបច្ចុប្បន្នឡើយ។

---

[62] Bouloc យោងរួចហើយនៅខាងលើ ទំព័រ ២៩២។

[63] ដូចខាងលើ។

[64] សាលក្រម *Blaskić* កថាខណ្ឌ ២៨៤ ; *រដ្ឋអាជ្ញា ទល់នឹង* *Mpambara*, ICTR-01-65-T, សាលក្រម (សាលក្រម *Mpambara*") ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៦ កថាខណ្ឌ ២២ ; *រដ្ឋអាជ្ញា ទល់នឹង* *Rutaganira*, ICTR-95-1C-T, សាលក្រម ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០៥ កថាខណ្ឌ ៦៤ ; *រដ្ឋអាជ្ញា ទល់នឹង* *Strugar*, IT-01-42-T, សាលក្រម ("សាលក្រម *Strugar*") ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៥ កថាខណ្ឌ ២៤៩។

[65] សូមមើល Gideon Boas, James L. Bischoff និង Natalie L. Reid, *International Criminal Law Practioner Library, ភាគ ១ - Forms of Responsibility in International Criminal Law* គ្រឹះស្ថានបោះពុម្ពផ្សាយ Cambridge University Press (ឆ្នាំ ២០០៧) ទំព័រ ៣១០-៣១៤។ ពួកគេគូសបញ្ជាក់ថា ការបកស្រាយនេះនាំឱ្យមានការកំណត់យកធាតុផ្សំនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ផ្អែកលើការរំលោភកាតព្វកិច្ចក្នុងការប្រព្រឹត្ត ក្នុងឋានៈជាថ្នាក់លើ។ ដូច្នេះ ការសមគំនិតក្រោមទម្រង់ជាអំពើអកម្ម មានតែធ្វើឱ្យការបែងចែកនេះកាន់តែមានមិនច្បាស់លាស់ និងធ្វើឱ្យយុត្តិសាស្ត្រមានភាពស្រពេចស្រពិលប៉ុណ្ណោះ។

### ii. ធាតុផ្សំសត្យានុម័តទីពីរ៖ ទំនងទំនងហេតុនិងបច្ច័យ

ផ្អែកលើចំណងទាក់ទងរវាងហេតុ និងបច្ច័យ ដែលតាមរយៈនោះ អំពើសមគំនិតត្រូវតែបានបង្កើតនូវផលវិបាកជាសំខាន់ដល់ការប្រព្រឹត្តឧក្រិដ្ឋកម្ម។ ជាទូទៅ អំពើនោះស្តែងឡើងជាអំពើដែលកើតមានមុន ឬកើតមានដំណាលគ្នានឹងអំពើចម្បង។ អង្គជំនុំជម្រះមួយចំនួននៃតុលាការពិសេស បានសម្រេចថា អំពើទាំងឡាយណាដែលកើតក្រោយការប្រព្រឹត្តបទល្មើស អាចត្រូវបានចាត់ទុកថាជាអំពើនៃការជួយ ឬផ្តល់ជំនួយ។ ដោយឡែក ការកំណត់បទល្មើសចំពោះទង្វើទាំងនេះអាចធ្វើទៅបាន អាស្រ័យទៅលើការវិភាគអំពីផលវិបាកជាសំខាន់ដែលបង្កើតឡើងដោយអំពើសមគំនិតនោះទៅលើការប្រព្រឹត្តបទល្មើស។ ជាក់ស្តែង វាជារឿងមួយដែលលំបាក ហើយពុំអាចធ្វើទៅរួច នៅក្នុងការបង្ហាញអំពីចំណងហេតុនិងបច្ច័យ នាពេលក្រោយនោះ (*a posteriori*)[66]។ ហេតុដូច្នេះហើយបានជា នៅក្នុងប្រព័ន្ធច្បាប់បារាំង អំពើនៃការជួយ ឬផ្តល់ជំនួយ ដែលប្រព្រឹត្តនៅក្រោយពេលដែលបទល្មើសបានប្រព្រឹត្ត មិនត្រូវបានគេពិចារណាឡើយ និង/ឬ ត្រូវបានចាត់ទុកជាបទមជ្ឈឹមដោយឡែក[67]។

### ខ. ធាតុផ្សំអត្តនោម័តនៃបទសមគំនិត

៦៣. ធាតុផ្សំអត្តនោម័តនៃបទសមគំនិតត្រូវបានបំបែកចេញជាពីរតូចៗទៀត គឺ៖ ទីមួយ ជនសមគំនិតត្រូវតែបានសម្រេចចិត្តច្បាស់លាស់ក្នុងការធ្វើសកម្មភាពទាំងឡាយដែលខ្លួនបានដឹងជាមុនថា ទង្វើនោះនឹងជួយសម្រួលដល់ការប្រព្រឹត្តបទល្មើស[68]។ ទីពីរ ជនសមគំនិតត្រូវតែបានដឹងអំពីធាតុផ្សំ

---

[66] ពាក់ព័ន្ធនឹងប្រការនេះ សូមមើល៖ សាលក្រម *Strugar* កថាខណ្ឌ ៣៥៥ និង *រដ្ឋអាជ្ញា ទល់នឹង* *Blagojević និង Jokić*, IT-02-60-T, សាលក្រម ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ កថាខណ្ឌ ៧៣១ និង ៧៤៥។ តាមពិត នៅក្នុងរឿងក្តីទាំងនេះ ទំនាក់ទំនងហេតុ និងបច្ច័យ ត្រូវបានស្តែងឡើង តាមរយៈការបង្ហាញពីអំពើលើកមុន (ការព្រមព្រៀង) ដែលជំរុញឲ្យប្រព្រឹត្តបទល្មើសតាមរយៈការសន្យាជួយក្រោយពេលប្រព្រឹត្តបទល្មើស។

[67] សូមមើល Mayaud យោងរួចហើយនៅខាងលើ។ សូមមើលផងដែរ៖ Crim., ថ្ងៃទី ៦ ខែ សីហា ឆ្នាំ ១៩៤៥, *Gaz.Pal.*, 1945.2.143; *Rev. sc.crim*, 1946.67, obs. Hugueney ; ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ១៩៤៧ ព្រឹត្តិបត្រឧក្រិដ្ឋកម្មលេខ ២៣៩ ; ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៩៧, *D.*, 1999. 28, កំណត់សម្គាល់របស់ Boccara; *នីតិព្រហ្មទណ្ឌ* ឆ្នាំ ១៩៩៧, obs. J.-H. Robert។

[68] *រដ្ឋអាជ្ញា ទល់នឹង Kunarac និងអ្នកផ្សេងទៀត* IT-96-23-T និង IT-96-23/1-T, សាលក្រម ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ

សំខាន់ៗនៃបទល្មើស រួមទាំងធាតុផ្សំអត្តនោម័ត/ខាងបញ្ញា ដែលជំរុញឲ្យចារីធ្វើការប្រព្រឹត្តបទល្មើស[69]។ ជាមួយគ្នានេះ អំពើនៃការជួយ ឬផ្តល់ជំនួយត្រូវតែជាអំពើចេតនា៖ អ្នកផ្តល់ជំនួយត្រូវតែបានដឹងច្បាស់អំពីផលវិបាកនៃការជួយរបស់ខ្លួន ហើយខ្លួនបានធ្វើវាដោយស្ម័គ្រចិត្ត[70]។

៦៤. ហេតុដូច្នេះហើយបានជា ជនសមគំនិតត្រូវតែបានដឹងអំពីការចូលរួមរបស់ខ្លួនទៅក្នុងការប្រព្រឹត្តបទល្មើស ក្នុងពេលដែលខ្លួនកំពុងធ្វើសកម្មភាពជួយ ឬផ្តល់ជំនួយដល់ចារីដែលនោះ។ ដូចគ្នានេះដែរ តុលាការកំពូលបារាំងបានដាក់លក្ខខណ្ឌថា ជនសមគំនិតត្រូវតែបានដឹងអំពីការចូលរួមរបស់ខ្លួនទៅក្នុងការប្រព្រឹត្តបទល្មើស នៅខណៈដែលខ្លួនកំពុងជួយ ឬផ្តល់ជំនួយដល់ការប្រព្រឹត្តបទល្មើសនោះ[71]។ ផ្ទុយទៅវិញ ការណ៍ដែលជនសមគំនិតបានដឹងនាពេលក្រោយថា ការជួយ ឬផ្តល់ជំនួយរបស់ខ្លួនបានជំរុញ ឬជួយសម្រួលដល់ការប្រព្រឹត្តបទល្មើស ទង្វើនេះពុំមែនជាអំពើសមគំនិតដែលត្រូវផ្តន្ទាទោសឡើយ ដោយហេតុថា ជនសមគំនិតពុំមានចេតនាក្នុងការធ្វើអំពើនោះឡើយ[72]។

៦៥. ដោយហេតុថាអំពើសមគំនិតអាចត្រូវបានផ្តន្ទាទោសបានតែក្នុងករណីដែលគេរកឃើញថា ជនសមគំនិតមានចេតនាប្រព្រឹត្តអំពើសមគំនិតនោះ ដូច្នេះ សហព្រះរាជអាជ្ញាត្រូវលើកបង្ហាញភ័ស្តុតាងដែលថា ជនសមគំនិតបានដឹងយ៉ាងច្បាស់អំពីទង្វើរបស់ខ្លួន ហើយខ្លួនបានដឹងនៅពេលដែលខ្លួនបានប្រព្រឹត្តអំពើនោះផងដែរថា ការជួយ និងការផ្តល់ជំនួយរបស់ខ្លួនពិតជាបានជួយដល់ការប្រព្រឹត្តបទល្មើស។

---

២០០១ កថាខណ្ឌ ៣៩២។

[69] *រដ្ឋអាជ្ញា ទល់នឹង Simić*, IT-95-9-A, សាលដីកា ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៦ កថាខណ្ឌ ៨៦ ; សាលក្រម *Mpambara* កថាខណ្ឌ ១៧ ; *រដ្ឋអាជ្ញា ទល់នឹង Aleksovski*, IT-95-14/1-A, សាលដីកា ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០០ កថាខណ្ឌ ១៦២។

[70] Mayaud យោងរួចហើយនៅខាងលើ ទំព័រ ៣៣៥-៣៤០។

[71] Crim. ថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ១៩៤៣, DA ឆ្នាំ ១៩៤៤, ២៩ ; ប៉ារីស ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៧៧, *RJ Com.*, ឆ្នាំ១៩៧៨ ទំព័រ ៤១៩, កំណត់សម្គាល់របស់ B. Bouloc ; Crim. ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៩៥, ព្រឹត្តិបត្រលេខ *២៤១* ; Crim. ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩០ ព្រឹត្តិបត្រលេខ ៣៨៨, Gaz. Pal., ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ១៩៩១ កំណត់សម្គាល់របស់ J.-P. Doucet ដែលអះអាងថា ធាតុផ្សំនៃចេតនាប្រព្រឹត្តបទល្មើស ត្រូវតែពិចារណា ក្នុងពេលប្រព្រឹត្តបទល្មើស។

[72] Bouloc យោងរួចហើយនៅខាងលើ ទំព័រ ៣០១។

## ៣. ការទទួលខុសត្រូវព្រហ្មទណ្ឌផ្ទាល់ខ្លួនក្នុងឋានៈជាអ្នកញុះញង់ អ្នករៀបចំផែនការ និង/ឬ អ្នកដែលមានអំណាចបញ្ជាលើជនជាប់ចោទ

៦៦. និយមន័យធាតុផ្សំទាំងឡាយនៃទម្រង់នៃការទទួលខុសត្រូវទាំងនេះ មានលក្ខណៈដូចគ្នាទាំងស្រុង ផ្អែកតាមយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិ ហេតុដូច្នេះហើយយើងពុំចាំបាច់បកស្រាយអំពីចំណុចទាំងនោះ នាដំណាក់កាលនេះឡើយ។[73]

៦៧. ផ្ទុយទៅវិញ វាជាការសំខាន់ក្នុងការរំលឹកថា ធាតុផ្សំទាំងឡាយនៃទម្រង់នៃការទទួលខុសត្រូវទាំងនេះ ក៏ដូចជាករណីនៃបទសមគំនិតដែរ ត្រូវបានប្រមូលផ្តុំនៅជុំវិញចំណងហេតុនិងបច្ច័យរវាងអំពើរបស់ជនជាប់ចោទ និងអំពើរបស់ចារីដែដល់។ ដូច្នេះ រាល់អន្តរាគមន៍ទាំងឡាយរបស់ជនជាប់ចោទដែលកើតមានក្រោយការប្រព្រឹត្តបទល្មើស ពុំត្រូវបានគេពិចារណាឡើយ ដោយហេតុថា គេអាចបង្កហេតុ រៀបចំផែនការ ឬអាក់ខានមិនបានទប់ស្កាត់ តែចំពោះហេតុការណ៍ដែលកើតមានក្នុងពេលអនាគតប៉ុណ្ណោះ។ ដូចគ្នានេះផងដែរ ធាតុផ្សំអត្តនោម័តសម្រាប់ទម្រង់នៃការទទួលខុសត្រូវទាំងនេះត្រូវតែកើតមានឡើងក្នុងពេលដំណាលគ្នានឹងអំពើសកម្ម ឬអកម្មរបស់ជនជាប់ ចោទ។

៦៨. **ហេតុដូច្នេះ** មេធាវីការពារក្តីលោក ខៀវ សំផន សូមស្នើដល់អង្គជំនុំជម្រះសាលាដំបូងមេត្តា៖

- **ប្រកាស និងសម្រេចថា** ធាតុផ្សំសត្យានុម័តនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាមទារឲ្យមានអត្ថិភាពនៃផែនការ និងនយោបាយរបស់រដ្ឋ ហើយធាតុផ្សំអត្តនោម័តនៃឧក្រិដ្ឋកម្មនេះទាមទារឲ្យមានចំណងទាក់ទងដោយផ្ទាល់ និងរឹងមាំរវាងការដឹងរបស់ជនជាប់ចោទអំពីបរិបទនៃការវាយប្រហារ និងការប្រព្រឹត្តនូវបទឧក្រិដ្ឋពីសំណាក់ចារីដែដល់។
- **ប្រកាស និងសម្រេចថា** ធាតុផ្សំសត្យានុម័តនៃឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញ ទាមទារឲ្យមានចំណងទាក់ទងរវាងអំពើនៃការធ្វើទុក្ខបុកម្នេញ និងឧក្រិដ្ឋកម្មដទៃទៀតដែលស្ថិតក្រោមយុត្តាធិការរបស់ អ.វ.ត.ក.។

---

[73] ក៏ប៉ុន្តែ បើនិយាយពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការទទួលខុសត្រូវរបស់ជនជាប់ចោទដែលអាចមិនមែនជាអ្នកប្រព្រឹត្តបទឧក្រិដ្ឋ មិនអាចរាប់បញ្ចូលបានឡើយ ទៅតាមទម្រង់នៃការទទួលខុសត្រូវទាំងនេះ ។ សូមអាន កថាខណ្ឌទី១៨ និងការកាត់សេចក្តី Milutinovic កថាខណ្ឌទី១៥៨ ដូចសម្រង់ខាងលើ កំណត់ជើងទំព័រ នៃទំព័រទី២១។

- **ប្រកាស និងសម្រេចថា** ឧក្រិដ្ឋកម្មនៃ "ការបាត់ខ្លួនដោយបង្ខំ" មិនអាចអនុវត្តទៅលើសំណុំរឿង ០០២/ ០១ បានឡើយ។
- **ប្រកាស និងសម្រេចថា** ការកំណត់បទល្មើសសហឧក្រិដ្ឋកម្មរួមក្នុងទម្រង់មូលដ្ឋានទាមទារឲ្យមានការបង្ហាញពីសំណាក់ព្រះរាជអាជ្ញា នូវអត្ថិភាពនៃផែនការឧក្រិដ្ឋកម្មច្បាស់លាស់ ដែលជនជាប់ចោទបានដឹងអំពីផែនការនោះ ហើយដែលជនជាប់ចោទបានចូលរួមយ៉ាងជាក់ច្បាស់តែ ម្តង។
- **ប្រកាស និងសម្រេចថា** ច្បាប់ដែលអាចអនុវត្តបានទៅលើបទសមគំនិតតាមរយៈការជួយ ឬការលើកទឹកចិត្ត ត្រូវតែបានបកស្រាយដោយផ្អែកលើមូលដ្ឋាននៃប្រព័ន្ធច្បាប់បែបបរាំង ដែលប្រព័ន្ធច្បាប់នេះតម្រូវឲ្យមានការបង្ហាញពីសំណាក់អយ្យការ នូវសកម្មភាពជាវិជ្ជមានរបស់ជនជាប់ចោទដែល សកម្មភាពនោះបានជះឥទ្ធិពលយ៉ាងជាក់ច្បាស់ចំពោះការប្រព្រឹត្តបទល្មើសមួយ ឬច្រើនហើយ ដែលបទល្មើសនោះស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក.។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន<br>មេធាវី Anta GUISSÉ<br>មេធាវី Arthur VERCKEN<br>មេធាវី Jacques VERGÈS | ភ្នំពេញ<br>ភ្នំពេញ<br>ប៉ារីស<br>ប៉ារីស | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |